**BBI0078**

**សម្ភាសន៍ជាមួយឈ្មោះគឺ សាំង ហេង ភេទប្រុស អាយុ៥៦ឆ្នាំ**

**មានស្រុកកំណើតនៅភូមិ ឃុំបាស្រែ ស្រុកព្រៃកប្បាស ខេត្តតាកែវ**

**សព្វថ្ងៃរស់នៅភូមិគគីរ ឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង**

**សម្ភាសន៍ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១១**

**មុខងារសម័យខ្មែរក្រហមៈ ទាហានខ្មែរក្រហម**

**មុខងារបច្ចុប្បន្នៈ កសិករ**

**សម្ភាសន៍ដោយៈ ស សេងគា**

**សរុបទំព័រៈ ៤៩**

**០១:២៨:៤២**

សេងគាៈ មុននឹងសួរខ្ញុំសូមណែនាំឈ្មោះឲ្យពូបានដឹងផងដែរ ខ្ញុំឈ្មោះ សេងគា ខ្ញុំនៅស្រុកបាត់ដំបងនេះទេ នៅស្រុកឯកភ្នំ ហើយខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយមកនេះដូចខ្ញុំបានប្រាប់ពូអំបាញ់មេញអញ្ចឹង ខ្ញុំគ្រាន់តែចង់ដឹងពីសាច់រឿងរបស់ពូ ពីប្រវត្តិផ្ទាល់ខ្លួនរបស់ពូឆ្លងកាត់ពីសម័យទៅសម័យមួយយ៉ាងម៉េចដែរ ដូចខ្ញុំអីកើតអត់ទាន់ទេរបបហ្នឹងដូច្នេះហើយមិនអាចសរសេរទាន់ទេក៏មានអាប់ជាសម្លេងទុក ហើយពូអត់ថាម៉េចទេ?

ហេងៈ អត់អីទេ ។

សេងគាៈ អញ្ចឹងខ្ញុំចង់ស្គាល់ឈ្មោះពូ តើពូឈ្មោះអីដែរ?

ហេងៈ ខ្ញុំឈ្មោះគឺ សាំងហេង ។

សេងគាៈ ពូអាយុប៉ុន្មានហើយ?

ហេងៈ អាយុ៥៦ហើយ ។

សេងគាៈ ស្រុកកំណើតរបស់ពូនៅណាដែរពូ?

ហេងៈ ស្រុកកំណើតកើតហ្នឹង?

សេងគាៈ បាទ!

ហេងៈ នៅភូមិព្រៃបាសឹង ឃុំបាស្រែ ស្រុកព្រៃកប្បាស ខេត្តតាកែវ ។

សេងគាៈ បច្ចុប្បន្ននៅភូមិអី?

ហេងៈ បច្ចុប្បន្ននៅភូមិអូរគគី ឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង ។

សេងគាៈ ឪពុកពូឈ្មោះអីដែរ?

ហេង៖ ឪពុកខ្ញុំឈ្មោះគី ស្រេង តែគាត់ស្លាប់ហើយ ។

សេងគា៖ ស្លាប់ពីពេលណាមក តាំងពីសម័យខ្មែរក្រហមឬក៏ពេលណាមក?

ហេង៖ ស្លាប់មិនមែនខ្មែរក្រហមទេ គឺផុតខ្មែរក្រហមហើយ ។

សេងគា៖ ទាល់តែហួសហើយ សម័យ៩០ជាងហើយមែនពូ?

ហេង៖ បាទ! ស្លាប់ហ្នឹងផុតខ្មែរក្រហមហើយ ពេលរដ្ឋកម្ពុជាចូលនៅរស់បានប៉ុន្មានហ្នឹង ។

សេងគា៖ គាត់ចាស់ដែរហើយពូ?

ហេង៖ ចាស់ហើយ ។

សេងគា៖ ចុះម្ដាយពូ?

ហេង៖ ម្ដាយនៅរស់ ។

សេងគា៖ ម្ដាយឈ្មោះអីពូ?

ហេង៖ ឡាក់ ព្រឹម ។

សេងគា៖ គាត់នៅរស់ទេ?

ហេង៖ បាទ!

សេងគា៖ រាល់ថ្ងៃគាត់នៅជាមួយពូទេ?

ហេង៖ អត់ទេគាត់នៅស្រុក ។

សេងគា៖ នៅស្រុកព្រែកប្បាស?

ហេង៖ បាទ!

សេងគា៖ ពូមានបងប្អូនប៉ុន្មាននាក់?

ហេង៖ មានបងប្អូន៨នាក់ ។

សេងគា៖ បងប្អូនបង្កើតរបស់ពូ?

ហេង៖ បាទ!

សេងគា៖ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ហេង៖ ប្រុសមានតែខ្ញុំមួយហ្នឹង ហើយស្រី៣នាក់ កាលសម័យប៉ុល ពត គេវ៉ៃចោលអស់ហើយ ។

សេងគា៖ អញ្ចឹងស្លាប់អស់ហើយ ។

ហេង៖ ស្លាប់អស់ហើយ ។

សេងគា៖ សល់តែពូមួយទេ?

ហេង:	សល់តែខ្ញុំមួយគត់ ខ្ញុំធ្វើខ្មែរក្រហមរស់ ។

សេងគា:	អញ្ចឹងពួកគាត់អត់ធ្វើខ្មែរក្រហមទេ?

ហេង:	ពួកគាត់ស្លាប់មុនយួនចូលហ្នឹង គេហៅយកមកវៃចោលទាំងម្ដាយ ម្ដាយនៅតែ៣ថ្ងៃទៀត កុំតែយួនចូលទាន់កុំអីគេយកទៅវៃចោលដែរហើយ ។

សេងគា:	ហើយកាលនោះស្លាប់នៅសម័យណាពូ កាលហ្នឹងឆ្នាំ១៩០០ប៉ុន្មានពូ?

ហេង:	ស្លាប់មុនយួនចូល កាលឆ្នាំ៧៩ហ្នឹង ។

សេងគា:	ឆ្នាំ៧៩ហើយ?

ហេង:	ហ្នឹងអើយ កាលហ្នឹងជិតយួនចូលហើយហ្នឹង ។

សេងគា:	អញ្ចឹងមានតែចុង៧៨?

ហេង:	អាចខ្វង់ប្រហែលហ្នឹង ដល់ពេលខ្លាំងអញ្ចឹងទៅតែខ្ញុំអត់ដឹងទេ ព្រោះខ្ញុំនៅព្រៃនៅតស៊ូនេះ ដែរហ្នឹងដល់ពេលទៅដល់ផ្ទះវិញស្លាប់បាត់ទៅ ។

សេងគា:	ហើយបងទី១របស់ពូឈ្មោះអីគេ?

ហេង:	ឈ្មោះ អេង ស្លាប់បាត់ហើយ ។

សេងគា:	ឈ្មោះអី អេង?

ហេង:	ឈ្មោះគី គឹមអេង ។

សេងគា:	ចុះទី២?

ហេង:	គី គឹមស្រី ។

សេងគា:	ទី៣?

ហេង:	គី គឹមស្រាង ។

សេងគា:	អញ្ចឹងនៅពូមួយចុងក្រោយគេ?

ហេង:	បាទ!

សេងគា:	ហើយពូមានកូនប៉ុន្មាននាក់ដែរ ប្រពន្ធពូឈ្មោះអីគេ?

ហេង:	សន វី ។

សេងគា:	គាត់អាយុប៉ុន្មានហើយឥលូវ?

ហេង:	អាយុ៤៦ ។

សេងគា:	មានកូនប៉ុន្មាននាក់ដែរពូ?

ហេង:	កូនមាន៥នាក់ ។

សេងគា: ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ហេង: ប្រុស៤នាក់ ហើយស្រីមានតែ១ទេ។

សេងគា: មានទាក់ទងហ្នឹងសម័យប៉ុល ពតទេកូនរបស់ពូ?

ហេង: កូនខ្ញុំមានទាន់២នាក់។

សេងគា: ទាន់២នាក់ដែរ?

ហេង: បាទ!

សេងគា: ហើយកូនទី១ឈ្មោះអីពូ?

ហេង: គឺ សាវ៉ន ហើយមួយទៀតឈ្មោះគឺ សាវុន, គឺ សាវឿន, គឺ សាវីន។

សេងគា: ឈ្មោះស្រដៀងគ្នាទាំងអស់ ស្រួលហៅណាស់បន្ទាប់ៗគ្នា ហើយកូនបងអាយុប៉ុន្មានកាលសម័យខ្មែរក្រហម?

ហេង: វាកើត៨៨។

សេងគា: អញ្ចឹងកើត៨៨ហើយ កាល៧៨អីអត់មានទេ?

ហេង: អត់ មានតែ៨៨ហើយ៩០។

សេងគា: អញ្ចឹងមានតែ៨៨ហើយ៩០ទេដែលទាន់?

ហេង: បាទ! កាលឆ្នាំ១៩៨៧កាលហ្នឹងហួសសង្គ្រាមមួយវគ្គហើយ ចូលសម័យ៧៩ហ្នឹងមួយវគ្គទៀត។

សេងគា: ពូរៀបការនៅឆ្នាំណា?

ហេង: រៀបការឆ្នាំ១៩៨៧ យកប្រពន្ធនៅឆ្នាំ១៩៨៧។

សេងគា: កាលនៅនោះអត់ទាន់មានប្រពន្ធទេ?

ហេង: អត់ទាន់មានទេ។

សេងគា: នៅយុវជនទេ?

ហេង: បាទ! កាលសង្គ្រាមលន់ នល់ឆ្នាំ៧៥ហ្នឹងអត់ទាន់មានប្រពន្ធទេ។

សេងគា: អញ្ចឹងខ្ញុំចង់ឲ្យពូរៀបរាប់ ពូចាំបានប៉ុណ្ណាយកប៉ុណ្ណឹងណាពូ អញ្ចឹងខ្ញុំចង់សួរពូកាលពូនៅកុមារភាពពូបានធ្វើអីខ្លះ?

ហេង: អត់មានធ្វើអីទេមានតែរៀនហ្នឹង។

សេងគា: កាលហ្នឹងពូចូលរៀននៅអាយុប៉ុន្មាន?

ហេង: កាលហ្នឹងក្មេចហើយដឹងតែនៅតូចដែរ កាលហ្នឹងដូចជាអាយុ៧-៨ឆ្នាំហ្នឹង។

សេងគាៈ រៀននៅសាលាណាពូ?

ហេងៈ សាលានៅស្រុក?

សេងគាៈ បាទ!

ហេងៈ រៀននៅសាលាបឋមសិក្សារំលក ។

សេងគាៈ រំលកហ្នឹងនៅក្នុងឃុំអីគេពូ?

ហេងៈ នៅក្នុងឃុំបាស្រែហ្នឹង ។

សេងគាៈ ចុះពូនៅរៀនហ្នឹងបានថ្នាក់ទីប៉ុន្មានដែរ?

ហេងៈ រៀនបានថ្នាក់ទី៧ ហើយរដ្ឋប្រហារឈប់ទៅ កាលរដ្ឋប្រហារលន់ នល់ហ្នឹង ។

សេងគាៈ មានរដ្ឋប្រហារក៏ឈប់ទៅ?

ហេងៈ បាទ! កាលហ្នឹងរដ្ឋប្រហារហើយគេធ្វើបាតុកម្មទៅក៏ឈប់ ។

សេងគាៈ ដល់ពេលឈប់ទៅពូចូលធ្វើទាហានតែម្ដង?

ហេងៈ បាទ!

សេងគាៈ គេចាប់មែន?

ហេងៈ អត់ចាប់ទេ ។

សេងគាៈ ពូស្ម័គ្រចិត្តចូល?

ហេងៈ កាលឈប់រៀនហ្នឹងបានប៉ុន្មានខែចូលសិល្បៈ ។

សេងគាៈ ចូលសិល្បៈ?

ហេងៈ ចូលសិល្បៈស្រុកព្រៃកប្បាសហ្នឹង ។

សេងគាៈ ឈប់រៀនបានប៉ុន្មានខែដែរបានចូលសិល្បៈ?

ហេងៈ បាន១ឆ្នាំដែរ កាល៧១-៧២ហ្នឹង ហើយគេបញ្ជូនមកធ្វើទាហាន ។

សេងគាៈ ខាងសិល្បៈខាងអីវិញពូ ខាងច្រៀង ខាងរាំ?

ហេងៈ ច្រៀងរាំដូចយើងដើរលេងអញ្ចឹង ដូចសម័យបដិវត្តន៍ហ្នឹង ។

សេងគាៈ កាលហ្នឹងគេរើសពូចូលធ្វើឬក៏ពូចូលខ្លួនឯង?

ហេងៈ គេរើសចូល ។

សេងគាៈ ខាងណាអ្នករើស?

ហេងៈ ងាប់ហើយអ្នករើស ។

សេងគាៈ ហ្នឹងអើយអ្នកងាប់ហ្នឹង?

ហេង៖ ឈ្មោះ សំ ហើយប្រធានសិល្បៈហ្នឹងឈ្មោះ ឡា ប៉ុន្តែអត់ស្គាល់ជីតាទេ សំ ហ្នឹងគណៈស្រុក ។

សេងគា៖ គណៈស្រុកព្រែកប្បាសហ្នឹងមែន?

ហេង៖ បាទ!

សេងគា៖ កាលហ្នឹងមានគ្នាច្រើនទេពេលដែលពូចូលសិល្បៈហ្នឹង?

ហេង៖ ច្រើនដែរ ។

សេងគា៖ ពូអាចនៅចាំមិត្តភ័ក្ត្ររបស់ពូ១-២នាក់បានទេកាលនៅសិល្បៈជាមួយគ្នាហ្នឹង?

ហេង៖ នៅចាំបាន ។

សេងគា៖ មានពីណាគេខ្លះ?

ហេង៖ ឈ្មោះ ខន ប្រុស ហើយមានម្នាក់ទៀតឈ្មោះ នោ ហ្នឹងស្រី ។

សេងគា៖ អញ្ចឹងពូនៅហ្នឹងគេឲ្យរាំតាមភូមិពេលមានកម្មវិធី?

ហេង៖ អត់ទេ ដូចថាស្រុកអញ្ចឹងស្រុកណាត្រូវមានគេធ្វើបុណ្យធ្វើម្ទេញអីហ្នឹង ពេលធ្វើម្ទេញគេយកសិល្បៈហ្នឹងទៅលេងទៅ នៅវត្តនៅអីមានកម្មវិធីគេយកទៅលេងមួយយប់អញ្ចឹងទៅដល់ក្រោយមកគេបញ្ជូនមកធ្វើទាហាន ។

សេងគា៖ កាលនៅសិល្បៈហ្នឹងមានប៉ុន្មាននាក់ពូ?

ហេង៖ ច្រើនដែរ កាលហ្នឹងមាន៣០នាក់ ។

សេងគា៖ មានស្រីមានប្រុសទៅ?

ហេង៖ បាទ!

សេងគា៖ សុទ្ធតែយុវជនមែនពូ?

ហេង៖ ហ្នឹងអើយ ។

សេងគា៖ ហើយសិល្បៈហ្នឹងអ្នកនៅខេត្តណា អ្នកនៅខេត្តតាកែវទាំងអស់ឬក៏នៅខេត្តផ្សេង?

ហេង៖ សុទ្ធតែអ្នកនៅខេត្តតាកែវ គ្រាន់តែស្រុកផ្សេងគ្នា ខ្លះស្រុកបាទី ហើយអ្នកខ្លះទៀតនៅស្រុកអីផ្សេងទៀតអញ្ចឹងណា ហើយភូមិខុសគ្នា ។

សេងគា៖ ហើយពូនៅរបាំបានប្រហែលប៉ុន្មានឆ្នាំដែរ?

ហេង៖ ខ្ញុំនៅបានតែមួយឆ្នាំទេ ។

សេងគា៖ អញ្ចឹងដល់ពេលឆ្នាំ១៩៧២គេបញ្ជូនពូមកធ្វើទាហាន?

ហេង៖ បញ្ជូនមកធ្វើទាហាន ។

សេងគាៈ ពីណាគេអ្នកបញ្ជូន គណៈស្រុក សំ ហ្នឹងមែន?

ហេងៈ បាទ! គណៈស្រុកគេបញ្ជូន គេរើស ។

សេងគាៈ មិនមែនពូចង់មកទេ គេបញ្ជូនពូមកទេ?

ហេងៈ គេបញ្ជូនមក ។

សេងគាៈ គេបញ្ជូនទាំងអស់គ្នាឬក៏បញ្ជូនតែពូទេ?

ហេងៈ មានអ្នកស្ម័គ្រចិត្តខ្លះ ព្រោះបើយើងនៅក៏នៅមិនបាន មកទៅអាខ្លះគេរត់ទៅផ្ទះទៅ ។

សេងគាៈ ហើយកាលទៅរៀនសិល្បៈរៀននៅកន្លែងណា?

ហេងៈ រៀននៅព្រៃល្វា ។

សេងគាៈ សិល្បៈនៅព្រៃល្វា?

ហេងៈ មន្ទីរស្រុកនៅព្រៃល្វា ។

សេងគាៈ ដល់ពេលពូ សំ បញ្ជូនឲ្យធ្វើទ័ពទៅធ្វើនៅកន្លែងណាទៅ?

ហេងៈ នៅកំពង់ស្ពឺ ចូលជាមួយទាហានចាស់ៗ ព្រៃក្មេង ។

សេងគាៈ កំពង់ស្ពឺព្រៃក្មេង?

ហេងៈ បាទ!

សេងគាៈ ភូមិអីគេ ភូមិព្រៃក្មេងហ្នឹងមែន?

ហេងៈ ខ្ញុំមិនសូវស្គាល់ដែរ តែភូមិព្រៃក្មេងខេត្តកំពង់ស្ពឺហ្នឹងហើយ ។

សេងគាៈ ដឹងតែខេត្តកំពង់ស្ពឺ នៅកន្លែងព្រៃក្មេង?

ហេងៈ បាទ!

សេងគាៈ ហើយបញ្ជូនទៅធ្វើទ័ពហ្នឹងគេដឹកឡានជូនទៅ?

ហេងៈ ដើរទៅ ។

សេងគាៈ នាំគ្នាដើរទៅ ដើរទៅកំពង់ស្ពឺ ដើរប៉ុន្មានថ្ងៃបានមកដល់ហ្នឹងពូ?

ហេងៈ យូថ្ងៃដែរ ៣-៤-៥ថ្ងៃដែរហ្នឹង ។

សេងគាៈ ហើយពេលដែលហ្នឹងអ្នកណាគេអ្នកនាំមក?

ហេងៈ អត់ស្គាល់ដែរ ។

សេងគាៈ ទាហានមែនពូ?

ហេងៈ បាទ! ទាហាន ។

សេងគាៈ ពេលនាំមកហ្នឹងគ្នាវាប៉ុន្មាននាក់ទៅពូ?

ហេង៖ គ្នាច្រើនដែរហ្នឹង ។
សេងគា៖ ប្រហែលជាប៉ុន្មានរយនាក់?
ហេង៖ គ្នាវាច្រើន មួយអនុសេនាធំប្រហែលជា១០០នាក់ជាងហើយមើលទៅ ។
សេងគា៖ អាហ្នឹងកងរយ?
ហេង៖ បាទ!
សេងគា៖ គេឲ្យពូទៅខាងអនុវរៈសេនាធំ?
ហេង៖ អត់ទេ ខ្ញុំនៅកន្លែងមន្ទីរ ។
សេងគា៖ មន្ទីរអីគេពូ?
ហេង៖ មន្ទីរដូចថាយើងនៅផ្ទះអញ្ចឹងមិនមានមេ ធ្វើនារសាធ្វើអីគេហ្នឹង ។
សេងគា៖ អ៎គេឲ្យពូធ្វើនារសា?
ហេង៖ បាទ!
សេងគា៖ ធ្វើនារសារត់សំបុត្រពីណាទៅណាទៅ?
ហេង៖ អត់បានទៅណាទៅណីទេ គ្រាន់តែស្ពាយទឹកស្ពាយអង្រឹងឲ្យគេហ្នឹង ។
សេងគា៖ តែប៉ុណ្ណឹងទេ?
ហេង៖ ហើយចងកន្លែងដេកឲ្យគេ ហើយនៅតូចៗណា៎ ដាំទឹកដាំអីឲ្យគេហូបទៅ ។
សេងគា៖ កាលហ្នឹងពូអាយុប៉ុន្មាន?
ហេង៖ ខ្ញុំអាយុ១៦ឆ្នាំ ។
សេងគា៖ ហើយប្រធានពូឈ្មោះអី ប្រធាននៅកន្លែងនារសាហ្នឹង?
ហេង៖ ជំនាន់ហ្នឹង?
សេងគា៖ បាទ!
ហេង៖ ឈ្មោះ ផល ប៉ុន្តែស្លាប់អស់ហើយ ។
សេងគា៖ អញ្ចឹងគេឲ្យធ្វើជានារសា?
ហេង៖ បាទ! ធ្វើនារសាគ្រាន់មានការអីរត់ប្រាប់ទីនេះទីនោះ ហើយនាំសំបុត្របន្តិចបន្តួច ។
សេងគា៖ ប្រធានហ្នឹងប្រធានអីគេ?
ហេង៖ ប្រធានអនុសេនាធំ ។
សេងគា៖ ឈ្មោះ ផល ហ្នឹងអ្នកប្រើ?
ហេង៖ បាទ!

សេងគា៖ ហើយអនុ ផល ហ្នឹងឈ្មោះអីទៀត?

ហេង៖ អត់ស្គាល់ទេភ្លេចបាត់ហើយ ព្រោះយូហើយ ។

សេងគា៖ ស្គាល់តែ ផល ទេ ហើយ ផល ហ្នឹងជាមនុស្សយ៉ាងម៉េចដែរ គាត់កាចឬស្លូតទេ?

ហេង៖ គាត់ស្លូតហ្នឹង ។

សេងគា៖ ផល ហ្នឹងគាត់អ្នកស្រុកណាដែរ?

ហេង៖ អត់បានស្គាល់ផងភ្លេចបាត់ហើយ ។

សេងគា៖ ពេលដែលមកដល់កំពង់ស្ពឺមកដល់ឃើញគាត់តែម្តង?

ហេង៖ បាទ!

សេងគា៖ គាត់ឲ្យចូល ហើយនារសាជាមួយពូហ្នឹងមានប៉ុន្មាននាក់ទៅ?

ហេង៖ មាន៣នាក់ តែអត់ស្គាល់ឈ្មោះទេភ្លេចអស់ហើយ ។

សេងគា៖ ២នាក់ទៀតនៅខេត្តណាពូ?

ហេង៖ អត់ស្គាល់ទេ ។

សេងគា៖ ប៉ុន្តែប្រុសទាំងអស់មែន?

ហេង៖ សុទ្ធតែប្រុសទាំងអស់ហ្នឹង ។

សេងគា៖ ស្របាៗគ្នា?

ហេង៖ បាទ!

សេងគា៖ ពូធ្វើនារសានៅកន្លែងអនុសេនាធំបានប៉ុន្មានឆ្នាំទៅ?

ហេង៖ បាន២-៣ឆ្នាំដែរហ្នឹង ។

សេងគា៖ រហូតដល់ឆ្នាំ៧៥មែន?

ហេង៖ អាហ្នឹងអត់ធ្វើនារសារហូតទេ ក្រោយមកគេឲ្យកាន់កាំភ្លើងទៅវៃគេដែរហ្នឹង ។

សេងគា៖ អញ្ចឹងធ្វើនារសាបានប៉ុន្មានឆ្នាំទៅ?

ហេង៖ បានប៉ុន្មានឆ្នាំទេ កាល៧៣នៅនារសាដែរ ដល់ពេល៧៤គេឲ្យទៅវៃហ្នឹងគេ កាល៧៣-៧៤ហ្នឹងគេឲ្យស្ពាយកាំភ្លើងទៅតាមគេទៅ ។

សេងគា៖ កាល៧៤ហ្នឹង ផល អ្នកឲ្យកាន់កាំភ្លើងមែន?

ហេង៖ បែកមកនៅតាមក្រុមតាមកងហើយតែភ្លេចឈ្មោះ ។

សេងគា៖ កាលមកអនុសេនាធំហ្នឹងមានប៉ុន្មាននាក់ទៅ?

ហេង: មួយអនុសេនាធំមែន?

សេងគា: បាទ! មានប៉ុន្មានកងវរយ ។

ហេង: មួយកងវរយមាន៣អនុសេនាតូច ។

សេងគា: ចុះមួយអនុសេនាតូចមានប៉ុន្មាន?

ហេង: មាន១២នាក់ អាស័ប្រឡំមួយក្រុមមាន១២នាក់ ហើយមួយអនុសេនាតូចមាន៣៦នាក់ ដល់៣អនុសេនាតូចហ្នឹងបានមួយកងវរយ ។

សេងគា: ទាល់តែ៣ក្រុមបានមួយអនុសេនាតូច ។

ហេង: មួយអនុសេនាតូចហ្នឹង៣៦នាក់ ហើយ៣កងវរយមាន៤០នាក់ដែរហ្នឹង

សេងគា: ហើយទាល់តែអនុសេនាតូច៣បាន១អនុសេនាធំ?

ហេង: បាទ!

សេងគា: កងវរយហើយអនុសេនាធំដូចតែគ្នាមែន?

ហេង: ដូចគ្នា ដល់ពេលវរៈសេនាតូចហើយវរៈសេនាធំខុសគ្នា ។

សេងគា: ខុសគ្នាយ៉ាងម៉េចទៅវរៈសេនាតូចហើយវរៈសេនាធំ?

ហេង: វរៈសេនាតូចដូចថាមួយវរៈអញ្ចឹងទៅមានគ្នា១០០នាក់អញ្ចឹងទៅ ហើយវរៈសេនាធំមាន ៣០០អញ្ចឹងទៅ ។

សេងគា: ១០០នាក់អញ្ចឹងទៅណោះ?

ហេង: បាទ!

សេងគា: ដល់ពេលធំមាន៣០០-៤០០នាក់អញ្ចឹងទៅ?

ហេង: បាទ! ដល់ពេលកងពល៥០០នាក់ទៅ ។

សេងគា: ដល់ពេលកងពលធំជាងហ្នឹងទៀត?

ហេង: បាទ! កងពលធំជាងហ្នឹង ។

សេងគា: កងពលប្រហែលជាប៉ុន្មាន?

ហេង: កងពល៣វរៈសេនាធំ យើងគិតមើលទៅវាប្រហែលជា៤-៥រយនាក់ ៣វរៈសេនាតូច បាន១វរៈសេនាធំ ហើយ៣វរៈសេនាធំបានហៅកងពល ។

សេងគា: អញ្ចឹងជិតពាន់នាក់ដែរ?

ហេង: បាទ!

សេងគា: អញ្ចឹងពូនៅក្នុងកងពលមួយណាដែរពេលដែល ដល បញ្ជូនពូឲ្យទៅកាន់កាំភ្លើង?

ហេងៈ នៅចល័តមួយ ។

សេងគាៈ ចល័តមួយហ្នឹងនៅក្នុងណា ដូចថានៅក្នុងក្រុមឬក៏នៅណា?

ហេងៈ ខ្ញុំភ្លេចដែរព្រោះវាអត់ទាន់ឡើងវរៈ ។

សេងគាៈ អាហ្នឹងគេហៅអីចល័ត?

ហេងៈ អាហ្នឹងវាដូចយើងនៅវរៈសេនាតូចវរៈសេនាធំអញ្ចឹងណ៎ា វានៅចល័តមួយ ចល័តពីរ អញ្ចឹងណ៎ា មិនមែនកងចល័តនៅភូមិទេណ៎ា ។

សេងគាៈ ចល័តកងទ័ពមួយពីរ?

សេងគាៈ បាទ! ចុះពូនៅចល័តកងទ័ពទីប៉ុន្មាន ទី១ឬក៏២កាលហ្នឹង?

ហេងៈ ភ្លេចអស់ហើយ ។

សេងគាៈ ប៉ុន្តែដឹងតែគេបញ្ជូនទៅនៅកងចល័ត ។

ហេងៈ បាទ!

សេងគាៈ កាលនៅកងចល័តមានគ្នាប៉ុន្មាននាក់?

ហេងៈ មាន៥០ នាក់ ។

សេងគាៈ ហើយហាត់រាល់ថ្ងៃបានគេឲ្យទៅបាញ់មែន?

ហេងៈ អត់មានហាត់ផង ។

សេងគាៈ គ្រាន់តែកាន់កាំភ្លើងហើយបាញ់ហ្មង?

ហេងៈ បាទ!

សេងគាៈ កាលហ្នឹងគេឲ្យហាត់នៅណាដែរ នៅកំពង់ស្ពឺដែលឬក៏នៅណា?

ហេងៈ ដូចថាគេចូលច្រើនអញ្ចឹងបានគេហាត់ ហើយខ្ញុំចូលម៉ាស្រុករខ្ញុំក្មេងៗហ្នឹងគេហាត់ផង គេហាត់តាមក្រុមចាស់ៗហ្នឹង ដូចមួយក្រុមអញ្ចឹងគេដាក់២នាក់អញ្ចឹងទៅ ហើយគេរំលែកឲ្យក្មេងៗនៅចាំកន្ទែងអញ្ចឹង យើងក្មេងជាងគេអត់មានបានហាត់ផង អត់បានចូលសាលានុធាផង ។

សេងគាៈ ហើយកាន់កាំភ្លើងនឹងគេដែរ?

ហេងៈ អាហ្នឹងដល់ពេលយូទៅកាន់កាំភ្លើងនឹងគេដែរ ព្រោះធំហើយគេឲ្យកាន់១ឆ្នាំ២ឆ្នាំទៅ ។

សេងគាៈ ចុះគេបញ្ជូនពូឲ្យកាន់កាំភ្លើងហ្នឹងឆ្នាំប៉ុន្មាន?

ហេង:	ឆ្នាំ៧៨ ។

សេងគា:	ទាល់តែចុង៧៨បានគេឲ្យទៅវៃប្ញក៏ម៉េច?

ហេង:	៧៨ហ្នឹងចាប់ផ្តើមវៃហើយ ។

សេងគា:	វៃពីខាងណាទៅខាងណាពូ?

ហេង:	វៃពីខាងផ្លូវជាតិលេខពីរ ។

សេងគា:	ថ្នល់ជាតិលេខពីរ?

ហេង:	បាទ! ថ្នល់ជាតិលេខពីរ ថ្នល់ជាតិលេខ៣៨ ។

សេងគា:	កាលហ្នឹងពូនៅក្នុងកងចល័តហ្នឹងដដែលទេ?

ហេង:	កាលហ្នឹងគេមិនមែនហៅកងចល័តទេ គេហៅកងភូមិភាគពិសេសហើយ ។

សេងគា:	អញ្ចឹងពូឡើងពីកងចល័តហ្នឹងមកភូមិភាគពិសេស?

ហេង:	បាទ!

សេងគា:	ចុះម៉េចបានជាគេដំឡើងពូ?

ហេង:	គេរៀបចំកងទ័ពថ្មី ។

សេងគា:	គេរៀបចំកងទ័ពថ្មី ហើយយើងអ្នកចាស់បានឡើង?

ហេង:	ហ្នឹងអើយ ។

សេងគា:	ចុះមួយកងភូមិភាគពិសេសហ្នឹងមានប៉ុន្មាន កន្លែងកងរបស់ពូហ្នឹង?

ហេង:	ច្រើនដែរមួយកងពលដែរហ្នឹង អាហ្នឹងចូលអញ្ចឹងគេចូលគ្នាច្រើន ។

សេងគា:	ចុះម៉េញខ្ញុំសូមសួរពូថយក្រោយបន្តិច នៅកន្លែងកងទ័ពចល័តរបស់ពូពីណាគេប្រធានរបស់ពូ អ្នកណាគេជាប្រធាន ។

ហេង:	ឈ្មោះ ផល ឈ្មោះ ផល មានពីរមួយ ផល តូច ហើយមួយទៀត ផល វរៈសេនាធំ

សេងគា:	តែឈ្មោះ ផល ដែរ?

ហេង:	បាទ! ឈ្មោះ ផល ដែរ ។

សេងគា:	កាលហ្នឹងពូនៅចល័តបានប្រហែលជាប៉ុន្មាន?

ហេង:	បានមួយឆ្នាំ ហើយកម្លាំងចូលមកថែមទៀតគេរៀបកងទ័ពថ្មីគេអត់មានហៅកងទ័ពចល័តទៀតទេ រៀបចំជាកងទ័ពហ្នឹងគេដាក់ជាភូមិភាគពិសេសហ្មង អាហ្នឹងដូចថាមានសេដ្ឋមានអ្នកដោះស្រាយស្បៀងអីដោយខ្លួនឯង អត់មានទៅតាមតំបន់តាមអីទេ ។

សេងគា:	ចុះមួយភូមិភាគរបស់ពូហ្នឹងមានគ្នាប៉ុន្មាននាក់ ហើយពីណាគេប្រធានពូ?

ហេងៈ ភូមិភាគពីជិនាន់នោះ?

សេងគាៈ បាទ!

ហេងៈ ដូចថាមួយជាយខេត្តអញ្ចឹងទៅគេដាក់កងភូមិភាគពិសេសអញ្ចឹងទៅណា៎ ។

សេងគាៈ អាហ្នឹងខាង តាម៉ុក មែនទេ?

ហេងៈ អត់ទេ តាម៉ុក ផ្សេង ។

សេងគាៈ អញ្ចឹងពីណាគេអ្នកកាន់?

ហេងៈ អាហ្នឹងមានតែ កែវ សារឿន ហ្នឹងហើយ តាម៉ុក ហ្នឹងនៅលើ កែវ សារឿន ហ្នឹងដែរ តាម៉ុក ខាងភូមិភាគនារតីនេះហ្នឹង ។

សេងគាៈ ប៉ុន្តែខាងហ្នឹងគឺ តាសារឿន?

ហេងៈ បាទ! ដូចឥលូវគេហៅភូមិភាគ៥ ភូមិភាគ៦អញ្ចឹងទៅ ។

សេងគាៈ មេញឈ្មោះអី សារឿន?

ហេងៈ កែវ សារឿន ។

សេងគាៈ គាត់ជាប្រធាន?

ហេងៈ បាទ!

សេងគាៈ ឥលូវគាត់នៅរស់អត់ តាសារឿន?

ហេងៈ ងាប់បាត់ហើយ មេៗងាប់អស់ហើយអត់មានសល់ទេ សូម្បីតែអ្នកនៅស្រុកខ្ញុំហ្នឹងក៏ងាប់អស់ដែរ ។

សេងគាៈ កាលហ្នឹងបាញ់គ្នារាល់តែថ្ងៃហ្នង?

ហេងៈ បាទ!

សេងគាៈ ចុះអនុរបស់គាត់មានស្គាល់ទេពូ?

ហេងៈ អត់ស្គាល់ផង ភ្លេចបាត់ហើយ ។

សេងគាៈ ប៉ុន្តែពូនៅជាប់ជាមួយពួកគាត់ហ្នឹង?

ហេងៈ បាទ! គាត់ក្តាប់រួម ។

សេងគាៈ ហើយវ៉ៃរាល់ថ្ងៃទៅ?

ហេងៈ មិនមែនវ៉ៃរាល់ថ្ងៃទេ ទាល់តែមានផែនការណ៍អីទើបវ៉ៃ ប៉ុន្តែជិនាន់ហ្នឹងជិនាន់ លន់ នល់ ទេណា៎ ។

សេងគាៈ កាលហ្នឹង៧/៨មិនទាន់ចូលខ្មែរក្រហមទេ?

ហេង៖ ហ្នឹងអើយ ខ្មែរក្រហមមិនទាន់ចូលជាមួយរាជរដ្ឋាភិបាលយើងទេ ខ្មែរក្រហមវៃជាមួយ លន់ នល់ វៃជាមួយទាហាន...។

សេងគា៖ អញ្ចឹងពូខាងទាហានខ្មែរក្រហមហើយវៃជាមួយ លន់ នល់

ហេង៖ បាទ!

សេងគា៖ ហើយកាលហ្នឹងប្រយុទ្ធជាមួយលន់ នល់ ទេ?

ហេង៖ ហ្នឹងអើយ ។

សេងគា៖ ហើយឪពុកម្ដាយបងប្អូនពូនៅផ្ទះ?

ហេង៖ នៅផ្ទះ ខ្ញុំបែករហូតដល់ឆ្នាំ៩២-៩៣បានចូលផ្ទះ ដល់ពេលទៅផ្ទះម៉ែឪងាប់អស់ ។

សេងគា៖ ពូចេញពីហ្នឹងមកពូទៅហាត់នៅកំពង់ស្ពឺ?

ហេង៖ បាទ! ដល់ហើយវៃៗរហូតមកបានរំដោះភ្នំពេញ រំដោះភ្នំពេញនៅភ្នំពេញបាន៣ខែ ។

សេងគា៖ អ៊ំពូវៃរហូតដេញដល់ភ្នំពេញ?

ហេង៖ បែក លន់ នល់ ហើយហ្នឹង១៧មេសា យើងមិនបែកភ្នំពេញហើយយើងមិននៅភ្នំពេញ

សេងគា៖ ហើយពូវៃពីកន្លែងហ្នឹងរយៈពេលប៉ុន្មានខែបានទៅដល់ភ្នំពេញ?

ហេង៖ ចាប់ពី១មករាទៅ បើកយុទ្ធនាការដល់១៧មេសាចប់ ។

សេងគា៖ ចាប់ពី១មករា?

ហេង៖ ចាប់ពី១មករារហូតដល់១៧មេសាអាហ្នឹងឈ្នះភ្នំពេញហើយ ។

សេងគា៖ មេសាឆ្នាំ៧៥មែន?

ហេង៖ បាទ!

សេងគា៖ អញ្ចឹងពេលដែលពូវៃឈ្នះចូលភ្នំពេញអញ្ចឹង ភ្នំពេញមានសភាពយ៉ាងម៉េចដែរកាល ហ្នឹង?

ហេង៖ ដកប្រជាជនចេញអស់ ។

សេងគា៖ ដកប្រជាជនចេញទាំងអស់?

ហេង៖ ហ្នឹងអើយ គេជម្លៀសប្រជាជនចេញអស់ នៅសល់តែទាហាន ប៉ុល ពត ហ្នឹងឯង ។

សេងគា៖ ប៉ុន្តែកាលហ្នឹងបែកភ្នំពេញហ្នឹងមានតែច្រកពូទេអ្នកវៃឬក៏មានច្រកផ្សេងទៀត?

ហេង៖ ចូលគ្រប់មុខសញ្ញាតែខ្ញុំចូលខាងកប់ស្រូវ ។

សេងគា៖ ពូចូលខាងទំនប់កប់ស្រូវ?

ហេង៖ បាទ!

សេងគា៖ កាលហ្នឹងមានប៉ុន្មានមុខសញ្ញាពូមានចាំទេ?

ហេង៖ ច្រើនដែរ ។

សេងគា៖ មានប៉ុន្មានពូមានចាំទេ?

ហេង៖ មានខាងនារតី តែ តាម៉ុក ជាអ្នកដឹកនាំ ។

សេងគា៖ ខាងនារតី តាម៉ុក?

ហេង៖ ហើយខាងភូមិភាគពិសេសតា កែវ សារឿន ។

សេងគា៖ ហើយមានខាងណាទៀត?

ហេង៖ មានខាងខត្តរ មានខាងបូព៌ា តែខ្ញុំអត់សូវស្គាល់ទេ ។

សេងគា៖ ហើយគេមានពិធីជប់លៀងអីទេពេលដែលវ៉ៃបែក?

ហេង៖ អត់មានទេ អត់មានបានជប់លៀងអីផង ។

សេងគា៖ ហើយពូមានដឹងថាហេតុអីបានជាគេជម្លៀសប្រជាជនចេញទេ?

ហេង៖ អាហ្នឹងចេះតែតៗគ្នា ជម្លៀសដើម្បីរៀបចំហើយអត់ឃើញយកប្រជាជនមកដាក់វិញផង ប្រជាជនចេញឡើងអស់ ។

សេងគា៖ ពេលដែលវ៉ៃបែកភ្លាមអរសប្បាយណាស់មែនទេពូ?

ហេង៖ សប្បាយដែរហ្នឹង ។

សេងគា៖ ព្រោះអីយើងបានជ័យជំនះអញ្ចឹង កងទ័ពតែប៉ុណ្ណឹងទេតែកាលណាយើងឈ្នះយើងសប្បាយហើយ ជោគជ័យលើខ្មាំងអីហ្នឹង ។

ហេង៖ ប៉ុន្តែនៅវ៉ៃគ្នាទៀតនៅភ្នំពេញហ្នឹង ទាហានចេញអស់ហើយវានៅគប់គ្រាប់បែកមិនចេះតិច វានៅលើផ្ទះថ្មវាអត់ព្រមចេញនោះ ពួកប៉ាវាយើងឲ្យទម្លាក់អាវុធហើយវាលួចបោះគ្រាប់បែកមករបួសអញ្ចឹងទៅ ហើយទម្រាំតែរៀបចំហើយវាយូដែរហ្នឹង ៣-៤-៥ខែដែរហ្នឹង ។

សេងគា៖ រៀបចំ៣-៤-៥ខែបានអស់?

ហេង៖ បាទ!

សេងគា៖ ហើយកាលហ្នឹងពេលដែលជុំគ្នាហ្នឹងគេមានធ្វើមេទិញអីទេ ពេលដែលរៀបចំហើយ?

ហេង៖ អត់មានធ្វើអីផង ។

សេងគា៖ អត់មានឃើញ ប៉ុល ពត អីដើរមក ឬក៏ខៀវ សំផនទេ?

ហេង៖ អត់ដែលឃើញទេ ។

សេងគា៖ ប៉ុល ពត អឺអត់ដែលឃើញដែរ?

ហេង៖ អត់ ។

សេងគា៖ ចុះពូគេថា ប៉ុល ពត ហ្នឹងពេលប្រជុំអឺមកតែមួយភ្លែតៗទេអត់ឲ្យឃើញមុខទេ?

ហេង៖ ទៅប្រជុំអត់ដែលឃើញផង ។

សេងគា៖ គេថាគាត់មិនសូវបង្ហាញមុខ?

ហេង៖ បាទ!

សេងគា៖ តែពូតែឈ្មោះគាត់?

ហេង៖ ពូតែឈ្មោះ ។

សេងគា៖ ចុះ នួន ជា មានធ្លាប់ឃើញទេពូ?

ហេង៖ នួន ជា ធ្លាប់ឃើញព្រោះគាត់មកប្រជុំមួយភ្លែតដែរ ដូចខៀវ សំផន អឺគាត់ចុះមកមួយភ្លែតៗ ។

សេងគា៖ ចុះ អៀង សារី?

ហេង៖ អៀង សារី ស្គាល់ ជួបសឹងរាល់ថ្ងៃដែរហ្នឹង ។

សេងគា៖ ជួបនៅភ្នំពេញហ្នឹងមែនពូ?

ហេង៖ ដូចថាយើងនៅយាមតាមផ្លូវ ហើយគាត់ជិះឡានមកមើលអ្នកយាម ដូចថាប្រាប់យើងថាឡានមេឡានអឺកុំឲ្យចាប់អញ្ចឹងណា៎ ព្រោះចាប់ដូចថាគេទៅធ្វើការប្រទ្បំឃាត់ ហើយដល់ពេលយើងឃាត់ពេលល្ងាចគេប្រជុំគេបន្ទោសយើង ថាចេះតែឲ្យចេញឲ្យចូលអញ្ចឹងមានខ្មាំងណាបន្តប់អញ្ចឹងគេចេះតែថាទៅណា៎កាលជំនាន់ហ្នឹង តែដល់ពេលយើងចាប់ថាយាមហ្នឹងឲ្យមើលផង មើលថាឡានណាមេហើយឡានណាកូនអញ្ចឹង ក្រែងលវាស្ទះការងារគេធ្វើការ ។

សេងគា៖ អញ្ចឹងគេឲ្យពូអ្នកយាម?

ហេង៖ អត់ទេយាមគ្រប់កងហ្នុង មិនមែនយាមតែម្នាក់ទេ ។

សេងគា៖ យាមគ្រប់កង?

ហេង៖ បាទ! ដូចថាមួយច្រកយើងកន្លែងផ្លូវជាតិលេខ២អញ្ចឹងទៅគេមកពីនោះយើងយាមកន្លែងអញ្ចឹងទៅ ហើយដូចថាយាមនៅមួយក្រុមអញ្ចឹងណា៎ គេឲ្យយាមតាមផ្លូវហ្នឹង ផ្ទះថ្មជាប់ហ្នឹង ហើយស្អែកឡើងការងារអត់មានអឺទេមានតែដើរប្រមូលសម្ភារៈដែលសល់ៗដែលគេបោះចោលនៅភ្នំពេញហ្នឹង យើងប្រមូលដាក់មួយដុំៗទៅ ។

សេងគា: ពូខ្ញុំចង់ឲ្យពូជួយរៀបរាប់ពីសភាពការណ៍កន្លែងដែលឡើងដល់ភ្នំពេញចប់ហើយវាម៉េចអី ម៉េចពូអាចជួយរៀបរាប់បានទេ?

ហេង: កាលចូលភ្នំពេញហ្នឹងមានអីមានតែប្រជាជនចេញហ្នឹង ។

សេងគា: ដល់ពេលប្រជាជនចេញហើយយ៉ាងម៉េចទៀត?

ហេង: ឲ្យប្រជាជនចេញហើយកងទ័ពហ្នឹងគេ ពួកខ្ញុំគេបញ្ជូនមករតនៈគិរីអត់មានបាននៅហ្នឹងយូដង ។

សេងគា: អញ្ចឹងនៅពេលដែលរៀបចំនៅហ្នឹង៣ខែ ហើយមកប្រជុំវិញហ្នឹងខាងពូ ដល ហើយពូសារឿន ហ្នឹងគេឲ្យមកនៅខាងម្តុំណាវិញ?

ហេង: នៅកន្លែងបឹងស្រយ៉ាបនេះ ស្គាល់ទេ?

សេងគា: ស្គាល់ ហើយគេឲ្យនៅជុំគ្នាទៅ?

ហេង: បាទ! មួយភូមិភាគពិសេសហ្នឹង៣កងពល ។

សេងគា: ហើយ អៀង សារី, ខៀវ សំផន អីជិះឡានកាត់តាមហ្នឹងដែរ?

ហេង: គេនៅផ្សេង ទាល់តែរៀបចេញមករតនៈគិរីហើយបានគេឲ្យមកនៅភ្នំពេញ កាលបែកមុនដំបូងគេបែកឲ្យនៅតាមកៀនៗជាយ កាលដំបូងបែកភ្នំពេញនៅភ្នំពេញហ្នឹងដែរ នៅយាមណ៍ យាមតាមច្រកតាមអីហ្នឹងទៅ ដល់ពេលក្រោយមកបានគេជម្លៀសមកនៅតាមកៀនៗនេះ ។

សេងគា: កៀនៗខាងណាវិញ?

ហេង: អាកន្លែងស្រយ៉ាបនោះ បឹងស្រយ៉ាបហ្នឹង ហើយដល់ពេលមានផែនការណ៍បញ្ជូនកងទ័ពទៅតាមព្រំដែនហ្នឹង ទៅរតនៈគិរីទៅបានគេហៅទៅនៅយាមមួយខែអញ្ចឹងទៅ ។

សេងគា: នៅភ្នំពេញហ្នឹងសម្រាកម្តុំណាពូ?

ហេង: ម្តុំជិតពេទ្យលោកសង្ឃហ្នឹងឯង ។

សេងគា: ពេទ្យលោកសង្ឃនៅម្តុំណា កន្លែងហ្នឹងជាអីគេ?

ហេង: ជាមន្ទីរពេទ្យ ។

សេងគា: មន្ទីរពេទ្យលោកសង្ឃហ្នឹងមែន?

ហេង: បាទ!

សេងគា: នៅកន្លែងហ្នឹងហ្មង?

ហេង: ខ្ញុំដេកនៅហ្នឹងដែរហ្នឹង កាលបែកភ្នំពេញមុនដំបូងរបួសគេឲ្យសម្រាកនៅហ្នឹងតើ ។

សេងគា៖ ពីណាគេរបួស?

ហេង៖ ខ្ញុំ ។

សេងគា៖ ហេតុអីបានជារបួស?

ហេង៖ របួសកាលចូលភ្នំពេញហ្នឹង ។

សេងគា៖ របួសចំកន្លែងណា?

ហេង៖ បាក់ជើង ហើយនឹងដៃនេះ ។

សេងគា៖ គេបាញ់ត្រូវមែនពូ?

ហេង៖ វ៉ៃចូលភ្នំពេញហ្នឹងគេបាញ់ត្រូវ គេគប់គ្រាប់បែក ។

សេងគា៖ អ៎គេគប់គ្រាប់បែកទៅ?

ហេង៖ ហ្នឹងអើយ ហើយត្រូវកន្លែងនេះៗៗ ។

សេងគា៖ ត្រូវសព្វកន្លែង?

ហេង៖ ច្រើនដែរ កាលហ្នឹងបិះស្លាប់ដែរហ្នឹង ។

សេងគា៖ ហើយក្បាលបាញ់ត្រូវដែរ?

ហេង៖ ក្បាលហ្នឹងទើបតែត្រូវទេ ។

សេងគា៖ ខាងណាអ្នកគប់?

ហេង៖ ពួកប៉ារ៉ាជាមួយទាហាន លន់ នល់ ហ្នឹង ។

សេងគា៖ គប់ពីលើផ្ទះមកមែនពូ?

ហេង៖ បាទ!

សេងគា៖ តែគប់ពីលើផ្ទះហ្នឹងផ្ទះមួយណាពូ?

ហេង៖ លើផ្ទះថ្មតែមិនដឹងមួយណាទេ ។

សេងគា៖ អត់មានដឹងកន្លែងណាម្តុំណាទេ?

ហេង៖ អត់ ។

សេងគា៖ ហើយកាលត្រូវហ្នឹងត្រូវប៉ុន្មាននាក់ពូ ពេលគប់គ្រាប់បែកមកត្រូវ?

ហេង៖ ត្រូវ៣នាក់ ត្រូវកងធំម្នាក់ ។

សេងគា៖ មានស្គាល់ឈ្មោះគេទេ?

ហេង៖ ឈ្មោះអីទេ តែគាត់ស្លាប់បាត់ហើយហ្នឹង គាត់ខ្វាក់ភ្នែកមួយខាងឈ្មោះ ហឿន ។

សេងគា៖ គាត់ហ្នឹងនៅវរៈសេនាធំ?

ហេង៖ គាត់នៅអនុសេនាតូចហ្នឹង អត់ទាន់ឡើងវរៈផងហ្នឹង ។

សេងគា៖ ហើយពូរ៉ៃបែកអញ្ចឹងហើយអត់មានឡើងដំណែងទៀតទេ នៅតែ...?

ហេង៖ អត់ទេនៅយុទ្ធជនដដែល ។

សេងគា៖ យុទ្ធជនភូមិភាគដដែល?

ហេង៖ បាទ!

សេងគា៖ ហើយពូដេកនៅពេទ្យលោកសង្ឃហ្នឹងដេកបានប៉ុន្មានខែបានជា?

ហេង៖ យូដែរហ្នឹង ប្រហែលជិតមួយឆ្នាំដែរហ្នឹង ។

សេងគា៖ កាល៧៥ជិតមួយឆ្នាំហើយបានគេបញ្ជូនទៅ?

ហេង៖ បាទ! អត់ទេខ្ញុំទៅដេកពេទ្យនៅក្នុងព្រៃមួយម្តងហើយ អានោះទៅដេកប៉ុន្មាន២-៣ខែហ្នឹង មានពេទ្យនៅក្នុងព្រៃទៀតណា៎ តាជនជាតិគាត់នៅក្នុងហ្នឹង ឈ្មោះ តាប៉ែនៗស្គាល់ទេ?

សេងគា៖ តាប៉ែន?

ហេង៖ ឈ្មោះគាត់ តាប៉ែន ទេតែនៅក្នុងនេះគេហៅតា ជន់ ជឿន ។

សេងគា៖ អញ្ចឹងរបួសត្រូវគ្រាប់បែក?

ហេង៖ បាទ! ព្យាបាលនៅមុំអន្លុព្រលឹងនេះឯង ។

សេងគា៖ អញ្ចឹងព្យាបាលនៅពេទ្យលោកសង្ឃបានតែ២-៣ខែចេញទៅ?

ហេង៖ បាទ! អាហ្នឹងជាហើយគេឡូសម្រាកនៅហ្នឹង ហើយគេចាក់ថ្នាំចាក់អី ដល់ពេលហើយគេបញ្ជូនមកតែម្តង បញ្ជូនមកតាមកងយើងមកតាមកង ។

សេងគា៖ លោកពូត្រូវគ្រាប់បែកហើយបានទៅដេកពេទ្យលោកសង្ឃ?

ហេង៖ អាហ្នឹងអត់ទាន់នេះទេ គ្រាប់បែកហើយគេបញ្ជូនមក ។

សេងគា៖ គ្រាប់បែកមិនមែននៅភ្នំពេញទេ?

ហេង៖ មិនមែននៅភ្នំពេញទេ ។

សេងគា៖ អញ្ចឹងគ្រាប់បែកនៅណាវិញ?

ហេង៖ នៅជាយភ្នំពេញហ្នឹង ។

សេងគា៖ នៅជាយភ្នំពេញ?

ហេង៖ បាទ! នៅជិតពោធិ៍ចិនតុងហ្នឹង ដល់ពេលត្រូវរបួសហ្នឹងហើយគេសែងមកខាងក្រោយនេះហ្នឹង សែងមកក្នុងព្រៃនេះហ្នឹង ។

សេងគា៖ ដល់ហើយសែងមកក្រោយវិញ?

ហេង៖ បាទ! មកដេកពេទ្យបានគេរៀបចំហើយ ។

សេងគា៖ មកដេកពេទ្យនៅកន្លែងណាពូ?

ហេង៖ នៅពេទ្យអន្លុងព្រលឹង ដែលគេហៅពេទ្យព"៥" ពេទ្យតា ជន់ ជឿន ។

សេងគា៖ អ្នកដែលវះកាត់ហ្នឹងឈ្មោះ តាជឿន?

ហេង៖ បាទ!

សេងគា៖ គាត់ប្រធានពេទ្យហ្នឹង?

ហេង៖ គាត់ប្រធានពេទ្យធំ អត់ស្គាល់ដែរអញ្ចឹង?

សេងគា៖ អត់ ។

ហេង៖ ពេទ្យធំណាស់កាលហ្នឹង ឯកទេស ។

សេងគា៖ ជន់ ជឿន?

ហេង៖ បាទ! តែគាត់ស្លាប់បាត់ហើយមិនដឹង តែឮគេថានៅ ។

សេងគា៖ ប្រធានពេទ្យនៅកន្លែងហ្នឹង?

ហេង៖ បាទ!

សេងគា៖ ប្រធានពេទ្យទាំងអស់ឬក៏ប្រធានពេទ្យនៅកន្លែង...?

ហេង៖ ម៉ាភូមិភាគហ្នឹង ។

សេងគា៖ ភូមិភាគអីគេ?

ហេង៖ កន្លែងហ្នឹងមិនដឹងជាភូមិភាគអី ប្រហែលជាភូមិភាគឧត្ដរមិនដឹង ។

សេងគា៖ គាត់អ្នកវះកាត់ឲ្យពូ?

ហេង៖ អ្នកវះកាត់ហើយអ្នករបួសគាត់វះកាត់ទាំងអស់ហ្នឹង ។

សេងគា៖ អញ្ចឹងព្យាបាលជិតមួយឆ្នាំដែរបានមកដេកនេះ?

ហេង៖ អត់ដល់មួយឆ្នាំទេ ប្រហែលជា២ខែហ្នឹងគេរៀបចំហើយគេបញ្ជូនមកដេកនៅពេទ្យលោកសង្ឃហ្នឹងមួយសារទៀតហើយបានសាសន៍ទៅបានគេបញ្ជូនមករតនៈគិរីតាមកងពលហ្នឹង ។

សេងគា៖ បានតែ២ខែទេ?

ហេង៖ បាទ!

សេងគា៖ នៅពេទ្យលោកសង្ឃបានប៉ុន្មានខែដែរ?

ហេងៈ បាន៧ខែ ។

សេងគាៈ អញ្ចឹងបាន៨ខែ?

ហេងៈ បាទ!

សេងគាៈ ដល់ពេលរាងធូហើយបានគេបញ្ជូនទៅរតនៈគិរី?

ហេងៈ មិនទាន់ធូរទេ វាជាហើយគ្រាន់ថាដៃនៅរាងក្រងែងបន្តិចដើរមិនទាន់រួចណា៎ អញ្ចឹងគេត្រូវបញ្ជូនកងពលហ្នឹងមករតនៈគិរី អញ្ចឹងអ្នកនៅកងណានៅកងហ្នឹងវិញ គេបញ្ជូនមកតាមកង ។

សេងគាៈ អញ្ចឹងមានន័យថាពូត្រូវគ្រាប់បែកហ្នឹងវ៉ៃបែកភ្នំពេញហើយគេមកនៅបឹងស្រយ៉ាបហើយបានត្រូវគ្រាប់មែនទេ?

ហេងៈ បាទ! កំពុងវ៉ៃហ្នឹងរបួសមានទាន់នេះណា៎ ។

សេងគាៈ របួសមិនទាន់ជាទេ?

ហេងៈ មិនទាន់ជាទេ ។

សេងគាៈ នៅដេកពេទ្យនៅឡើយទេ?

ហេងៈ បាទ! ទើបតែប្រទាញប្រទង់គ្នាមិនទាន់យកបុស្តិ៍វិទ្យុបានទេ មកក្នុងព្រៃនេះបានមួយថ្ងៃ បានគេផ្សាយថាបដិវត្តន៍ហ្នឹងរំដោះហើយ ។

សេងគាៈ អញ្ចឹងកាលហ្នឹងនៅជិតកន្លែងពេទ្យអន្តព្រលឹងហ្នឹងព្រៃទេ?

ហេងៈ ពេទ្យក្នុងព្រៃទេ ។

សេងគាៈ នៅម្តុំណាពេទ្យហ្នឹង?

ហេងៈ អត់ស្គាល់ដែរ ។

សេងគាៈ មានចាំថានៅឃុំអី ស្រុកអីទេ?

ហេងៈ ថាជិតភូមិហ្នឹង ហួសពីភូមិហ្នឹងទៅវត្តអន្តព្រលឹង អាហ្នឹងមិនដឹងខេត្តអីអត់ស្គាល់ដែរ?

សេងគាៈ ប៉ុន្តែនៅជិតៗភ្នំពេញដែរ?

ហេងៈ មិនដឹងជិតឬក៏ឆ្ងាយបើភ្នំពេញមិនដែលស្គាល់ផង ។

សេងគាៈ នៅពោធិ៍ចិនតុង?

ហេងៈ ពោធិ៍ចិនតុងហ្នឹងយើងវ៉ៃដល់ហ្នឹងហើយ របួសហើយគេសែងយើងមកក្រោយវិញហ្នឹង ព្រោះមានកន្លែងណាដាក់អ្នករបួស ។

សេងគាៈ អញ្ចឹងគេសែងមកក្រោយវិញ?

ហេង៖ បាទ! ដល់ពេលរៀបចំហើយយើងដេញប្រជាជនចេញអស់ហើយបានយើងរៀបចំមន្ទីរពេទ្យហើយយើងសែងអ្នករបួសយើងទៅដាក់ក្នុងមន្ទីរពេទ្យវិញ ត្រលប់ត្រឡិនអញ្ចឹងឯង ។

សេងគា៖ ហើយពេលហ្នឹងពីណាគេជាអ្នកចាត់តាំងឲ្យទៅមជ្ឈិមភូមិភាគរបស់ពូហ្នឹងទៅខាងនេះ?

ហេង៖ មេនៅភ្នំពេញមិនដឹងពីណាទេ ។

សេងគា៖ ដឹងតែមេនៅភ្នំពេញ?

ហេង៖ បាទ!

សេងគា៖ ម៉េចបានជាគេចាត់តាំងឲ្យទៅខាងហ្នឹង?

ហេង៖ អាហ្នឹងគេចែកតាមកងពល ។

សេងគា៖ កងពលរបស់ពូគេឲ្យទៅខាងរតនៈគិរីទាំងអស់ហ្នឹងទៅ?

ហេង៖ បាទ!

សេងគា៖ ដឹកនាំដោយពូ សារឿន ហ្នឹងដែរ?

ហេង៖ អត់ទេ អាហ្នឹងមានមេមួយទៀត មេ សោម ។

សេងគា៖ សោម ហ្នឹងធំជាង តាសារឿន ឬក៏តូចជាង?

ហេង៖ ធំជាង ព្រោះអគ្គមេបញ្ជាការគេហើយហ្នឹង ។

សេងគា៖ ហើយពូ សារឿន ហ្នឹងទៅជាមួយដែរ?

ហេង៖ ពូ សារឿន ហ្នឹងមេកងពល ។

សេងគា៖ អញ្ចឹងនៅបានប្រហែលជារយៈពេល៨-៩ខែ?

ហេង៖ នៅបាន៨-៩ខែហ្នឹងគេបញ្ជូនទៅរតនៈគិរីអស់ទៅ ហើយក្រោយមកមិនដឹងអ្នកណាទៀតទេ ។

សេងគា៖ មេបញ្ជាការឈ្មោះអីគេម៉េញ?

ហេង៖ ឈ្មោះ សោម ។

សេងគា៖ គាត់នៅរស់ឬក៏ស្លាប់ពូ?

ហេង៖ ស្លាប់បាត់ហើយ គេថាខ្មែរក្បត់ខ្មែរអីណាសាប់បាត់ហើយ ។

សេងគា៖ ទៅរតនៈគិរី?

ហេង៖ បាទ!

សេងគា៖ ពេលដែលពូទៅរតនៈគិរីពូជិះឡានទៅមែន?

ហេង៖ ជិះកាណូត កាលហ្នឹងកប៉ាល់២-៣ ។

សេងគា៖ កប៉ាល់៣ហ្នឹងទាំងអស់មានគ្នាប៉ុន្មាននាក់?

ហេង៖ មួយកប៉ាល់មានមួយវរៈសេនាធំ ច្រើនដែរហ្នឹង ។

សេងគា៖ អញ្ចឹង៣វរៈសេនាធំ?

ហេង៖ បាទ!

សេងគា៖ ដែលដឹកនាំដោយ តាសោម?

ហេង៖ បាទ! កាលហ្នឹងមានកាំភ្លើងមានគ្រាប់ដាក់ទៅ ។

សេងគា៖ អញ្ចឹងគាត់ដឹកនាំទៅ ហើយពេលទៅអត់មានប្រយុទ្ធគ្នាទេពូ?

ហេង៖ អត់ទេ ។

សេងគា៖ ទាល់តែទៅដល់រតនៈគិរីហ្នុង?

ហេង៖ កាលហ្នឹងជិនាន់ហ្នឹងឈប់បាញ់គ្នាហើយ ។

សេងគា៖ អ៎កាលខ្មែរក្រហមឈប់បាញ់គ្នាហើយ?

ហេង៖ ឈប់បាញ់គ្នាហើយមានស្អីទៀត ទើបតែរដ្ឋកម្ពុជាយើងទំនាស់ផ្ទៃក្នុងនេះហ្នឹងបានបាញ់គ្នាជាមួយយួនជាមួយអីហ្នឹងទៅ កាលនោះអត់មានអ្នកណាទាន់បាញ់គ្នា ទើបតែឆ្នាំ៧៧-៧៨នេះបានចាប់ផ្តើមគេដេញប៉ុល ពត ចេញពីភ្នំពេញហើយរដ្ឋកម្ពុជាយើងមិននេះអញ្ចឹងបានប្រទូសរ៉ាយគ្នាទៅ ។

សេងគា៖ ហើយកាលដែលពូទៅហ្នឹងជិះកាណូតប៉ុន្មានថ្ងៃបានទៅដល់ ហើយឈប់នៅកន្លែងណាជិះពីភ្នំពេញយើងទៅមែន?

ហេង៖ បាទ! ពីស្ពានជ្រោយចង្វារយើងហ្នឹង ហើយទៅដេកនៅកំពង់ចាមមួយយប់ ។

សេងគា៖ ដេកកំពង់ចាម?

ហេង៖ បាទ! ដល់បើកមួយយប់ទល់ភ្លឺហ្នុងដល់កំពង់ចាមភ្លឺ ហើយចេញពីកំពង់ចាមទៅដេកនៅក្រចេះកន្លែងព្រែកគគី្ហើយជិះឡានទៅតែម្តង ជិះឡាន៣-៤ថ្ងៃទៀតបានដល់ ។

សេងគា៖ កំពង់ចាមហើយទៅណាទៀត?

ហេង៖ កំពង់ចាមហើយដេកព្រែកគគីនៅក្រចេះណ៎ ។

សេងគា៖ បាទ!

ហេង៖ ឡើងពីក្រចេះហ្នឹងទៅបានជិះឡានហ្នឹងទៅ ។

សេងគា៖ ជិះឡានទៅដល់ហ្នឹងហ្នុង?

ហេង៖ បាទ!

សេងគា៖ ឡានហ្នឹងឡានទាហានគេមកយកមែន?

ហេង៖ ឡានទាហាន ។

សេងគា៖ ហើយពេលដែលពូទៅដល់រតនៈគិរីពូនៅម្តុំណា នៅកងពលណា?

ហេង៖ នៅកងពល៨០១ ។

សេងគា៖ ហើយ តាសោម ហ្នឹងជាអគ្គបញ្ជាការ?

ហេង៖ តាសោម ហ្នឹងនៅភ្នំពេញ ។

សេងគា៖ អ៎តាសោម នៅភ្នំពេញ គាត់អត់ទៅទេ?

ហេង៖ អត់ទៅទេ ទៅតែកែវ សារឿន ។

សេងគា៖ ទៅតែ កែវ សារឿន ហើយ តាសោម គាត់ជាអ្នកបញ្ជាឲ្យទៅ?

ហេង៖ ហ្នឹងអើយ ។

សេងគា៖ អញ្ចឹងនៅពេលដែលទៅដល់នោះគេឲ្យធ្វើអីទៀតទៅ?

ហេង៖ ទៅដល់ហ្នឹងមានធ្វើអីកាប់តែព្រៃហ្នឹង ។

សេងគា៖ កាប់ព្រៃដែរ?

ហេង៖ កាប់ព្រៃ ធ្វើចំការ ធ្វើស្រែធ្វើអីហ្នឹង ជំនាន់ហ្នឹងធ្វើស្រែដែរហ្នឹង ។

សេងគា៖ ធ្វើស្រែរហូតដល់ឆ្នាំណា?

ហេង៖ រហូតដល់ឆ្នាំ៧៦-៧៧បានចាប់ផ្តើម ។

សេងគា៖ រហូតដល់៧៧?

ហេង៖ ៧៧ហ្នឹងវ៉ៃគ្នាមួយសារទៀតហើយ ។

សេងគា៖ វ៉ៃគ្នាជាមួយអ្នកណាគេ?

ហេង៖ ជាមួយយួន យួនទាហានខ្មែរហ្នឹងឯងតាមមើល វ៉ៃខ្មែរហើយខ្មែរគ្នាឯងហ្នឹង ។

សេងគា៖ បែបវ៉ៃគ្នាខ្លាំងហើយពេលហ្នឹង?

ហេង៖ វ៉ៃខ្លាំងដែរហ្នឹង ។

សេងគា៖ ហើយពូអត់មានទៅណាទេ វ៉ៃនៅហ្នឹងរហូត?

ហេង៖ នៅហ្នឹងរហូតទាល់តែគេបែកភ្នំពេញបានឈប់ ។

សេងគា៖ ដល់ពេលបែកភ្នំពេញឆ្នាំ៧៩ហ្នឹងបានឈប?

ហេង៖ បាទ!

សេងគា៖ តែអត់មានត្រូវរបួសអីទៀតទេ?

ហេង៖ មានរបួសម្តងដែរ ។

សេងគា៖ មានរបួសម្តងទៀត?

ហេង៖ របួសជើង ។

សេងគា៖ ត្រូវអីគេពូ?

ហេង៖ នាំសំបុត្រឲ្យគេហើយទាហានយួនវាបុកមកហើយវាបាញ់ត្រូវអំបែងខ្មាត ។

សេងគា៖ អញ្ចឹងពូធ្វើនារសាទៀត?

ហេង៖ ហ្នឹងអើយគេឲ្យធ្វើនារសាទៀត នាំសំបុត្រឲ្យគេ ។

សេងគា៖ នាំសំបុត្រឲ្យ តាសារឿន ហ្នឹង?

ហេង៖ អត់ទេ ដូចថាយើងនាំរបាយការណ៍ពីកន្លែងមួយទៅកន្លែងមួយទៀតអញ្ចឹងណា៎ ។

សេងគា៖ ពីណាគេជាអ្នកឲ្យបញ្ជូនមក?

ហេង៖ ភ្លេចឈ្មោះហើយ ។

សេងគា៖ ចុះក្រោមប៉ុល សារឿន មានពីណាគេទៀត?

ហេង៖ ក្រោមប៉ុល សារឿន មាន តាយន ។

សេងគា៖ តាយន?

ហេង៖ តាយន, តានួន អាហ្នឹងសុទ្ធតែប្រធានកងវរៈ ។

សេងគា៖ ហ្នឹងគាត់ប្រធានកងវរៈ?

ហេង៖ បាទ!

សេងគា៖ ទាំងពីរហ្នឹងសុទ្ធតែប្រធានកងវរៈទាំងពីរ?

ហេង៖ បាទ!

សេងគា៖ អ្នកដែលដឹកនាំពូមួយណា តាយន ឬក៏ តានួន?

ហេង៖ ខ្ញុំនៅជាមួយ តាយន ប៉ុន្តែក្នុងមួយកងវរៈហ្នឹងមានមេ៣នាក់ មានប្រធាន មាន អនុប្រធាន ។

សេងគា៖ ហើយមានពីណាគេទៀត?

ហេង៖ អត់ស្គាល់ផង ។

សេងគា៖ ហើយចុះអនុមួយទៀត?

ហេង៖ អត់ស្គាល់ដែរ ។

សេងគា: តែមេរបស់ពូនៅជាមួយ តាឃន?

ហេង: បាទ!

សេងគា: ហើយពូរត់សំបុត្រហ្នឹងត្រូវ?

ហេង: បាទ!

សេងគា: កាលហ្នឹងឆ្នាំប៉ុន្មាន?

ហេង: ឆ្នាំ៧៧ ។

សេងគា: ហើយត្រូវនៅកន្លែងណាពូ?

ហេង: ត្រូវនៅជិតហាត់ប៉ក់ ស្គាល់ទេ?

សេងគា: អត់ស្គាល់ទេ ។

ហេង: នៅក្នុងព្រៃហ្នឹង ។

សេងគា: ហាត់ប៉ក់ហ្នឹងភូមិអីគេ?

ហេង: ឃុំវនសៃ ។

សេងគា: ត្រូវអំបែង?

ហេង: ត្រូវអំបែង ដាន់វាៗបុកមក ចុះវាដើរធ្វើការហើយវាដើរដែរនោះ ដល់ពេលបុកទៅបាញ់គ្នាហ្នឹងទៅងាប់ពីរនាក់ ពេលដែលខ្ញុំទៅនោះមានគ្នា៣នាក់ហើយងាប់២នាក់នៅសល់តែខ្ញុំម្នាក់ ។

សេងគា: អ៎ទៅ៣នាក់ជាមួយនារសាររបស់ពូហ្នឹងមែន មិត្តភ័ក្ត្រហ្នឹងគាត់អត់ទាន់ស្លាប់ទៅស្លាប់នៅនោះទេ?

ហេង: គេបាញ់ងាប់អ្នកក្រោយហើយខ្ញុំដើរមុនគេ ដល់ពេលអំបែងវាបុកមក ។

សេងគា: បុកពីក្រោយមក?

ហេង: អត់ទេ បុកចំពីមុខហ្នឹង ហើយខ្ញុំដាក់ប្រូងទៅវិញទៅវាបុកមកក្រាំងមក ងាប់អស់ពីរនាក់ហើយ នៅរស់តែខ្ញុំមួយហ្នឹង ។

សេងគា: ហើយសំបុត្រកាលហ្នឹងពូរត់ពីហ្នឹងយកទៅណា?

ហេង: យកទៅឲ្យតាមកងគេ ។

សេងគា: ពូមានដឹងថាក្នុងសំបុត្រគេដាក់ថាយ៉ាងម៉េចទេ?

ហេង: អត់ដឹងផង ។

សេងគា: គេបិទមែន?

ហេង៖ ហ្នឹងអើយ គេបិទឡើងជិត ។

សេងគា៖ ហើយយកទៅហុចឲ្យគេទៅ?

ហេង៖ បាទ!

សេងគា៖ ហើយពូយកសំបុត្រហ្នឹងមានកាន់កាំភ្លើងម្នាក់មួយដើមដែរ?

ហេង៖ សុទ្ធតែកាំភ្លើងហើយជំនាន់ហ្នឹង ហើយខ្ញុំកាន់អាវការបត់ ។

សេងគា៖ ពូអត់មានចាំឈ្មោះនារសា២នាក់ហ្នឹងទេ?

ហេង៖ អត់ ភ្លេចអស់ហើយព្រោះយូហើយ ចាំមួយឈ្មោះ យន អាហ្នឹងដើរក្រោយខ្ញុំហើយខ្ញុំដើរនាំមុខគេ ។

សេងគា៖ អញ្ចឹងពូសំណាងណាស់ ត្រូវចំអ្នកក្រោយ ។

ហេង៖ បាទ!

សេងគា៖ នៅពេលដែលត្រូវគ្រាប់ហើយពូរត់យកទៅឲ្យគេទៀតឬក៏ត្រលប់ក្រោយ?

ហេង៖ រត់ទៅមុខទៀត ។

សេងគា៖ យកសំបុត្រដល់គេ?

ហេង៖ ហ្នឹងអើយ ។

សេងគា៖ ហើយព្យាបាលប៉ុន្មានថ្ងៃទៅ?

ហេង៖ ប្រហែលជាមួយខែដែរហ្នឹងបានជា យកទៅហើយអត់មានបានត្រលប់មកវិញទេនៅព្យាបាលកន្លែងហ្នឹង ។

សេងគា៖ អញ្ចឹងពីទៅពីវរៈសេនាទីប៉ុន្មានហើយទៅដល់ទីប៉ុន្មានកាលហ្នឹង?

ហេង៖ ភ្លេចអស់ហើយ ។

សេងគា៖ ប៉ុន្តែដឹងតែពី តាប៉ុល សារឿន មក តានួន?

ហេង៖ បាទ! ពី តានួន ទៅទៀត

សេងគា៖ អញ្ចឹងពី តានួន ទៅទៀត?

ហេង៖ អត់ទេ តានួន ហើយ តាយន ហ្នឹងនៅជាមួយគ្នាទេ ប៉ុន្តែគ្រាន់តែ តាយន ហ្នឹងមេ ហើយ តានួន ហ្នឹងអនុ ។

សេងគា៖ អញ្ចឹងយកឲ្យហ្នឹងយកទៅឲ្យអ្នកណាមួយទៀត?

ហេង៖ យកឲ្យកងផ្សេងទៀត ។

សេងគា៖ កងផ្សេងទៀតហ្នឹងអត់ដឹងថាអ្នកណាប្រធានទេ?

ហេង: ភ្លេចបាត់ហើយ អ៎យកឲ្យ តាអែម ។

សេងគា: យកទៅឲ្យ តាអែម?

ហេង: បាទ!

សេងគា: អត់ដឹងថាសំបុត្រហ្នឹងគេដាក់ថាម៉េចទេ?

ហេង: អត់ដឹងទេ ព្រោះគេបិទជិតហើយ ។

សេងគា: កាលហ្នឹងកំពុងតែប្រយុទ្ធគ្នាក្តៅគគុកហើយណោះ?

ហេង: អាហ្នឹងមិនមែនយើងវ៉ៃគ្នារាល់ថ្ងៃទេ ដូចថាយើងឡើងធ្វើការទៅក្តាប់ទៅអីទៅអាហ្នឹងបាន នេះប៉ះគ្នាបានវ៉ៃ ។

សេងគា: វ៉ៃហ្នឹងវ៉ៃនៅចុង៧៧មែនពូ?

ហេង: ចុង៧៧ដើម៧៨ហ្នឹង ។

សេងគា: វ៉ៃរហូត?

ហេង: ហ្នឹងអើយ ។

សេងគា: វ៉ៃរហូតដល់៧៩មែនពូ?

ហេង: បាទ!

សេងគា: អញ្ចឹងពូដាពីជម្ងឺហើយវ៉ៃទៀត?

ហេង: វ៉ៃទៀត អត់ហ៊ានមកភូមិទេព្រោះខ្លាចគេបាញ់ចោល ព្រោះនយោបាយគេខ្ចាំងដែរហ្នឹង បើថាអ្នកទើបតែចូលអត់សួរអី បើពួក១២មេសាឲ្យតែរត់ចេញគេបាញ់ហើយ អញ្ចឹង ចាញ់នយោបាយគេខ្ចាំងដែរជិនាន់ហ្នឹង គេអ្នកចូលតែចេះតែរស់ទៅ បើយើងអត់ចូល ចេះតែសំងំនៅព្រៃហ្នឹងទៅ ដល់ពេលឆ្នាំ៩៦នេះផ្តាច់ខ្លួនចូលកន្លែងពីងពួយនេះទាក់ទង ទាហានឆ្នាំ៩៦ ។

សេងគា: ពូទៅទាក់ទងទាហានខ្លួនឯង?

ហេង: ខ្ញុំទៅទាក់ទងទាហានខ្មែរនេះ មិនទាហានខ្មែរក្រហម ។

សេងគា: ហើយ៩៦ពូមកនេះ?

ហេង: ៩២មកនេះ ហើយ៩៦ហើយគេធ្វើសាមារណកម្មហើយយើងទៅចចារគ្នានៅកំពីងពួយ បាត់ដំបងយើងនេះ ខ្ញុំទៅនៅកំពីងពួយហ្នឹងបានប៉ុន្មានយប់ដែរហ្នឹង ហើយទៅទាក់ទង ចចារគ្នាត្រូវហ្នឹងបានមេ គង់ យើងនេះចូលគណៈបក្សប្រជាជនយើងនេះចូលត្រូវគ្នាទាំង អស់អញ្ចឹងទៅបានអញ្ចឹងរហូតទៅបាត់ខ្មែរក្រហមទាំងអស់ ។

សេងគា: អញ្ចឹងពូនៅរតនៈគិរីរហូតដល់៧៩បានបកមកនេះ?

ហេង: ឆ្នាំ៨១បានឡើងមក ហើយឡើងមកធ្វើការនៅនោះទៀត ។

សេងគា: បានវិតពីអន្លុងវែងមក?

ហេង: ហ្នឹងអើយ ។

សេងគា: អញ្ចឹងបាញ់ពីរតនៈគិរីមកបាញ់តអញ្ចឹងមក?

ហេង: ហ្នឹងអើយ ។

សេងគា: អញ្ចឹងពូអាចរៀបរាប់ពីកន្លែងរតនៈគិរីវាងរហូតមកដល់នេះ ពូអាចរៀបរាប់ពីដំណាក់កាលហ្នឹងបន្តិចបានទេ?

ហេង: ឡើងនៅនោះ៨១ ប៉ុន្តែឡើងហើយយើងចុះទៅធ្វើការនៅក្រោមវិញហ្នឹង ទាល់តែមេៗហ្នឹងមានផែនការណ៍ត្រូវវៃជួយទប់ខាងនេះ ហើយពួកពេទ្យហ្នឹងមកខាងនេះ ពួកគា សុន សេន ហ្នឹង អញ្ចឹងមន្ទីរគា សុន សេន ទាំងប៉ុន្មានហ្នឹងគឺគាត់យកមកនេះឆ្នាំ៩២គេបញ្ជូនមកខាងនេះ បញ្ជូនមកនៅយើងច្រកខ្មែរនេះ ។

សេងគា: អញ្ចឹងខ្ញុំចង់ដឹង..?

ហេង: ៨១-៨២-៨៣-៨៥-៨៦ហ្នឹងនៅតែធ្វើការខាងក្នុងដដែលហ្នឹង ។

សេងគា: ខាងក្នុងហ្នឹងមានខាងរតនៈគិរី?

ហេង: អត់ដល់រតនៈគិរីទេ ឆ្លងទន្លេមកហើយ ។

សេងគា: ចប់៧៩បែកភ្នំពេញភ្លាមឆ្លងមកភ្លាម?

ហេង: ៨១បានឆ្លងមកព្រោះនៅសំងំនៅរតនៈគិរីហ្នឹង ។

សេងគា: ដល់ពេលហើយចេះតែអត់ឃ្លានវិញហើយ ព្រោះពេលប្រយុទ្ធអត់សូវមានអីហូបទេ?

ហេង: អត់មានអីហូបទេ ។

សេងគា: ហូបក្តូចហូបអីទៅ?

ហេង: បាទ! ដល់ពេលឆ្នាំ៨៦-៨៧ពួកចិនគេមក ចិនគេទៅថតទៅអីហ្នឹង គេទៅមើលទ័ពយើងមានស្អីខ្លះហ្នឹងពួកទូតគេហ្នឹង ពេលគេទៅមើលឃើញគេបើកស្បែកជើង បើកខោអាវឲ្យ ។

សេងគា: គេមកមើលទាហានខ្មែរក្រហមហ្នឹង?

ហេង: បាទ! ចុះកាលហ្នឹងមិន.... ។

សេងគា: សុទ្ធតែអ្នកគាំទ្រ?

| | |
|---|---|
| ហេង: | ហ្នឹងអើយសុទ្ធតែអ្នកគាំទ្រ ដឹកកាភ្លើង ដឹកឡានមកបើកពីចិនហ្នឹងឯង សុទ្ធតែកាំភ្លើងចិនគ្រាប់អីហ្នឹង ។ |
| សេងគា: | អញ្ចឹងមកហ្នឹងមកនៅអន្លុងវែង? |
| ហេង: | បាទ! |
| សេងគា: | ដំណាក់កាលឆ្នាំ៨១ បានឆ្លងពីរតនៈគិរីមក? |
| ហេង: | បាទ! |
| សេងគា: | ឆ្លងតាមអី? |
| ហេង: | ហែលទឹក ដើររហូត ។ |
| សេងគា: | ហែលទឹកពី? |
| ហេង: | ហែលទន្លេមេគង្គហ្នឹង ។ |
| សេងគា: | ហែលមករួចដែរ? |
| ហេង: | ស្លាប់ខ្លះ អ្នកណានៅរឹងដើងរឹងដៃក៏នៅរស់ទៅ ហើយអ្នកណាដែលគ្នាអាយុខ្ចីហ្នឹងក៏ស្លាប់ទៅ ។ |
| សេងគា: | ហើយមកហ្នឹងបណ្តែតខ្លួនមក? |
| ហេង: | ហែលមួយយប់ទល់ភ្លឺ ហើយយើងធ្វើក្បូនកាត់ឫស្សីកាត់អីចង ។ |
| សេងគា: | ចងដែរ? |
| ហេង: | ហើយចងហើយយើងដាក់កាំភ្លើងដាក់អីទៅ ហើយហែលមកដល់ពេលហែលមកចំទាហានខ្មែរហើយទាហានយួនហ្នឹងក៏ដាក់គ្នាទៅ អត់បាយអត់ទឹកទម្រាំតែមកដល់ភ្នំ ។ |
| សេងគា: | កាលហ្នឹងធ្វើក្បូនច្រើនទម្លាក់ពីនោះមក វរៈសេនាមកទាំងអស់? |
| ហេង: | មកទាំងអស់ ។ |
| សេងគា: | ហើយអ្នកណារស់ក៏រស់ទៅ? |
| ហេង: | ហ្នឹងអើយអ្នកណារស់ក៏រស់ទៅហើយអ្នកណាស្លាប់ក៏ស្លាប់ទៅ ។ |
| សេងគា: | ហើយ តាឃន គាត់នៅរស់ទេ? |
| ហេង: | នៅរស់ កាលជំនាន់ហ្នឹងនៅរស់ទេ ។ |
| សេងគា: | ហើយ តាសាឿន គាត់ជិះក្បូនមកជាមួយដែរ? |
| ហេង: | អត់ មិនដឹងថាគេទៅខាងណា ។ |
| សេងគា: | អញ្ចឹងគាត់អត់ហែលទឹកទេណោះ? |

ហេង: បាទ! មានតែកូនទាហានដែលហែល ។

សេងគា: មានតែកូនទាហានហើយគាត់មិនដឹងទៅខាងណាទេ?

ហេង: បាទ!

សេងគា: នៅទន្លេមេគង្គហ្នឹងចាប់ចំនុចណាមកចាប់ពីកំពង់ចាមមកមែន?

ហេង: មិនមែនហៅកំពង់ចាមទេ ហៅស្អីនេះខ្ញុំអត់ស្គាល់ដែរហ្នឹង ដូចជាទន្លេពេន កន្លែងហ្នឹងវាមានកោះបួន ។

សេងគា: កោះអីខ្លះពូ?

ហេង: អត់ស្គាល់ដែរហ្នឹង រំលងពីកោះបួនហ្នឹងបានឆ្លងមកអញ្ចេះ ស្គាល់តែទន្លេហ្នឹងគេហៅទន្លេពេន ទន្លេហ្នឹងបែបកាច់មិនដឹងតាមមើល ឆ្លងប្រឡោះហ្នឹងឯង កងពលអាចមកមុនព្រោះគេទាក់ទងមានទូកមានអីហ្នឹងចម្លងហើយបានហៅកងកម្លាំងមកតាមក្រោយ ។

សេងគា: ប្រហែលជាអញ្ចឹងហើយ ។

ហេង: មានផ្ទៃក្នុងដូចថាយើងទាក់ទងបានជាម៉ែជាឪទៅគេជម្លៀសមេៗមកមុនហើយ អាកូនមកតាមក្រោយហែលទឹកហ្នឹង ។

សេងគា: ស្លាប់ច្រើនទេពូ?

ហេង: ស្លាប់ច្រើនដែរ ។

សេងគា: ដល់ពេលចេញពីឆ្លងទន្លេហើយមកដល់ខេត្តណា?

ហេង: មកដល់ខេត្តព្រះវិហារ ។

សេងគា: មកដល់ព្រះវិហារ?

ហេង: បាទ!

សេងគា: ឆ្លងពីទន្លេមេគង្គមកដល់ព្រះវិហារ?

ហេង: បាទ! មកដល់ខេត្តព្រះវិហារ ។

សេងគា: អត់មានកាត់ស្ទឹងត្រែងទេ?

ហេង: អត់ទេ កាត់ព្រះវិហារហ្នឹងហើយបានឡើងមកដល់ភ្នំដងរែកនេះ ស្ទឹងចាន់យើងនេះ ។

សេងគា: ដើររហូតហ្នឹងពូ?

ហេង: ដើររហូតអត់មានឡានជិះទេ ។

សេងគា: នៅកន្លែងណាដែលឈប់យូជាងគេ?

ហេង: មកដល់លើភ្នំដងរែកហ្នឹង ។

សេងគា៖ មកដល់ភ្នំដងរែកឈប់នៅហ្នឹងទៅ?

ហេង៖ បាទ! នៅធ្វើជំរុំនៅហ្នឹងស្រ

សេងគា៖ កាលហ្នឹងជាមួយពីណាគេខ្លះពូ?

ហេង៖ ច្រើនណាស់ខ្ញុំមិនសូវស្គាល់គេទេ ។

សេងគា៖ ពីណាគេខ្លះមេធំៗ?

ហេង៖ មានតាកែវ សារឿន មាន តាម៉ៅ ហើយមាន តាយន ហើយមានមេច្រើនណាស់តែខ្ញុំមិនសូវស្គាល់គេទេ ។

សេងគា៖ ព្រោះអ្នកនៅខាងក្នុងច្រើនណាស់មេៗ?

ហេង៖ បាទ!

សេងគា៖ ចុះមានជួប តាម៉ុក នៅហ្នឹងទេ?

ហេង៖ អត់ទេ តាម៉ុក ប៉ែកខាងនេះផ្សេង ។

សេងគា៖ ចុះ តាអាន មានជួបទេ ។

ហេង៖ អឺអាន កាលហ្នឹងនៅគណៈតំបន់តើ ខាង៩២០ ។

សេងគា៖ មាន៩២០?

ហេង៖ បាទ! មាន៩២០ ហើយមានភាគកណ្តាល ហើយមានពួកតំបន់អញ្ចឹងទៅ ។

សេងគា៖ នៅជុំគ្នាទៅ?

ហេង៖ បាទ! ហើយពួកខ្ញុំនៅផ្សេងទៅ វាមានតែប៉ុន្មាននាក់ពេលហ្នឹង ។

សេងគា៖ ហើយនៅព្រះវិហារបានប៉ុន្មានថ្ងៃបានឡើងមកទៀត?

ហេង៖ អត់ទេទៅធ្វើការនៅព្រះវិហារវិញតើ ឡើងមកដល់លើភ្នំហើយចុះទៅធ្វើការនៅនោះវិញ ។

សេងគា៖ អញ្ចឹងឡើងចុះៗ?

ហេង៖ បាទ!

សេងគា៖ បានប៉ុន្មានបានមកទីនេះ ៩២មែនបានបកមកនេះ?

ហេង៖ ឆ្នាំ៩២បានដកមកនេះ ។

សេងគា៖ មេនាំមកមែន?

ហេង៖ អត់ទេ មេ សារឿន នៅនោះដដែលហ្នឹង ។

សេងគា៖ អញ្ចឹងមេ សារឿន អត់មកទេ?

ហេងៈ អត់ ។

សេងគាៈ អ្នកណាគេនាំមកអញ្ចឹង?

ហេងៈ តាសុន សេន ។

សេងគាៈ តាសុន សេន ឲ្យដកមកនេះ?

ហេងៈ ព្រោះយើងនៅមន្ទីរជាមួយគាត់ ។

សេងគាៈ អ៊ំពេលពូទៅហ្នឹងនៅមន្ទីរជាមួយគាត់ ជាមួយតាសុន សេន ហ្នឹង?

ហេងៈ បាទ!

សេងគាៈ សុន សេន ដកមកនេះដកគ្នាច្រើនទេពូ?

ហេងៈ ដកតែពួកឃ្លាំងហើយនឹងពួកពេទ្យ ។

សេងគាៈ មានគ្នាប៉ុន្មាននាក់ពូមានចាំខ្លះទេ?

ហេងៈ គ្នាមួយភូមិហ្នឹងសឹងតែទាំងអស់ហ្នឹង ។

សេងគាៈ សុទ្ធតែពួកឃ្លាំង?

ហេងៈ ពួកឃ្លាំងនៅខាងនោះ ។

សេងគាៈ អញ្ចឹងពូពួកពេទ្យ?

ហេងៈ ពួកពេទ្យពួកខ្ញុំនេះ ។

សេងគាៈ អញ្ចឹងកាលហ្នឹងពូធ្វើពេទ្យ?

ហេងៈ ធ្វើពេទ្យ ។

សេងគាៈ ដល់ពេលត្រូវរបួសច្រើនពេកគេឲ្យធ្វើពេទ្យវិញ?

ហេងៈ បាទ!

សេងគាៈ អ្នកណាអ្នកឲ្យធ្វើកាលហ្នឹង?

ហេងៈ មេគេឲ្យធ្វើ ។

សេងគាៈ មេហ្នឹង តាឃន?

ហេងៈ បាទ!

សេងគាៈ ធ្វើពីពេលណាមក?

ហេងៈ យូដែរហ្នឹងតាំងពី៨០ ប៉ុន្មានទេ ។

សេងគាៈ តាំងពីនៅព្រះវិហារ?

ហេង៖ បាទ! តាំងពីនៅហ្នឹង តាំងពីខ្ញុំមិនទាន់យកប្រពន្ធ កាលហ្នឹងប្រហែលជា៨៥ ព្រោះយកប្រពន្ធ៨៧ ។

សេងគា៖ អញ្ចឹងយកប្រពន្ធការនៅព្រះវិហារទៅ?

ហេង៖ បាទ! ការនៅហ្នឹង ។

សេងគា៖ ប្រពន្ធអ្នកស្រុកណាពូ?

ហេង៖ ប្រពន្ធនៅព្រែកប្បាសដែរហ្នឹង តែគាត់ទៅនៅរកស៊ីនៅសៀមរាប ប៉ុន្តែស្រុកកំណើតនៅស្នោរនេះហ្នឹង ។

សេងគា៖ ចុះពូតស៊ូអញ្ចឹងអត់មានឡើងឋានៈអីទេ?

ហេង៖ អត់បានឡើងអីផង កាលជំនាន់ហ្នឹងឡើងដែរហ្នឹង ឡើងបានត្រឹមវរៈសេនាតូច ។

សេងគា៖ ប្រធានវរៈសេនាតូច?

ហេង៖ បាទ! ដល់ពេលឈប់របួសទៅខ្ញុំធ្វើពេទ្យតែម្តង ។

សេងគា៖ ដល់ពេលធ្វើនារសាហើយ ហើយវរៈសេនាតូចធ្វើតាំងពីពេលណាមក?

ហេង៖ ធ្វើតាំងពីនៅវ៉ៃ ។

សេងគា៖ វ៉ៃនៅណា?

ហេង៖ វ៉ៃនៅរតនៈគិរី ដល់ពេលចេញពីរតនៈគិរីមកធ្វើយុទ្ធជន ដល់ពេលក្រោយមកពួក១២មេសាហ្នឹង ។

សេងគា៖ ចុះពូនៅវរៈសេនាតូចហ្នឹងពូក្តាប់បានប៉ុន្មាននាក់ កាលពូធ្វើប្រធានហ្នឹង?

ហេង៖ កាលជំនាន់ហ្នឹងបាន៥០ នាក់ហ្នឹង ។

សេងគា៖ អ៊ំពូកាន់បាន៥០ នាក់ដែរ?

ហេង៖ បាទ!

សេងគា៖ ខាងវរៈសេនាហ្នឹងកាន់ខាងកាំភ្លើងធំមែន?

ហេង៖ អត់ទេធ្វើមេនៅតាមកងអញ្ចឹងហ្នង ។

សេងគា៖ អ៊ំធ្វើប្រធាននៅតាមកង?

ហេង៖ បាទ!

សេងគា៖ ហើយកាលធ្វើវរៈសេនាហ្នឹងហូបចុកគ្រប់គ្រាន់ទេ?

ហេង៖ ជំនាន់ហ្នឹងហូបគ្រប់គ្រាន់តើ អង្ករអីចេញពីភ្នំទៅតើ គេជំនួយមក ។

សេងគា៖ ចិនជំនួយមកវិញ?

ហេង៖ បាទ! ហូបគ្រប់គ្រាន់ហើយ អាហ្នឹងលែងស៊ីក្តួចហើយ មកដល់លើភ្នំលែងស៊ីក្តួចហើយ កាលនៅរតនៈគិរីបានស៊ី ។

សេងគា៖ ចិនជួយរហូត?

ហេង៖ ជួយរហូត ។

សេងគា៖ ចិនដឹកចេញតាមច្រកថៃ?

ហេង៖ ហ្នឹងអើយ ។

សេងគា៖ កាលហ្នឹងចិនឲ្យច្រើន,

ហេង៖ ឲ្យមាស ឲ្យអង្ករ ឲ្យឡាន ឲ្យកាំភ្លើង ប៉ុន្តែថៃវាយកពាក់កណ្តាលព្រោះដឹកកប៉ាល់វា អញ្ចឹង មួយកប៉ាល់ហ្នឹង៣ខែបានអស់ព្រោះថៃយកពាក់កណ្តាល ។

សេងគា៖ អញ្ចឹងពួកថៃវាយកពាក់កណ្តាលចូលកន្លែងវា?

ហេង៖ ដូចថា១០ឡានអញ្ចឹង ហើយសម្ភារៈក្នុងឡានសុទ្ធតែពេញៗណា៎ បើថាកាំភ្លើងកាំភ្លើង អញ្ចឹងទៅ ហើយគ្រឿងស៊ីហ្នឹងមួយឡានហ្នឹងពេញ ចេញពីកប៉ាល់មកពេញៗមួយឡាន តែម្តង ហើយដូចថា១០គ្រឿងអញ្ចឹងយើងបានតែ៥ទេព្រោះថៃវាយក៥ទៅហើយ ។

សេងគា៖ ហើយពូធ្វើវរៈសេនាតូចបានប៉ុន្មានខែដែរ?

ហេង៖ ខ្ញុំធ្វើបានបន្តិចដែរហ្នឹង ប្រហែលជាជិតមួយឆ្នាំ ។

សេងគា៖ អញ្ចឹងធ្វើតាំងពីចុង៧៧រហូតដល់៧៨?

ហេង៖ ហ្នឹងអើយចុង៧៧-៧៨ហ្នឹងឯង អាមួយហឹកវៃខ្ទាំងហ្នឹង ពេលវៃខ្ទាំងគេចាត់តាំងអ្នក ចាស់ៗហ្នឹងឡើងមេក្រុមៗ អនុសេនាធំ វរៈសេនាតូចអញ្ចឹងទៅ ។

សេងគា៖ ហើយពូឡើងវរៈសេនាតូច?

ហេង៖ អត់ទេ អនុសេនាតូច ហើយបានឡើងអនុសេនាធំ ដល់ពេលឡើងអនុសេនាធំហ្នឹងបាន របួសមួយដងទៀតទៅបានគេថាពិបាកដែរហ្នឹងព្រោះរបួសញឹកដែរណា៎ អញ្ចឹងក៏គេឲ្យធ្វើ ពេទ្យទៅ ។

សេងគា៖ អ្នកណាគេដែលថាអញ្ចឹង តាយន មែន?

ហេង៖ មេ ។

សេងគា៖ ស្មានតែ តាយន ថារបួសច្រើនពេក ។

ហេង៖ អញ្ចឹងថាឲ្យយើងធ្វើពេទ្យម្តងទៅ ថាពេទ្យហ្នឹងរៀនបានប្រហែលជាមួយខែហ្នឹង គេឲ្យ រៀនរុំបង់ ចាក់ថ្នាំ មានបានរៀនអីណា ។

សេងគាៈ បាទ! អញ្ចឹងក៏ធ្វើពេទ្យរហូតទៅ?

ហេងៈ បាទ! ធ្វើពេទ្យរហូត ។

សេងគាៈ ចុះឥឡូវមានធ្វើពេទ្យទៀតទេពូ?

ហេងៈ ខ្ញុំឈប់ហើយ នៅស័គ្រចិត្តភូមិ ។

សេងគាៈ អញ្ចឹង?

ហេងៈ បាទ!

សេងគាៈ ស័គ្រចិត្តខាងពេទ្យដែរ?

ហេងៈ ខាងពេទ្យដែរហ្នឹង ពេលគេរងគ្រោះអី ពួកអង្គការគេបង្រៀន ។

សេងគាៈ ជួយតាមអង្គការវិញ?

ហេងៈ បាទ!

សេងគាៈ ពូអាត្រែត?

ហេងៈ អត់អាត្រែតទេ គឺឈប់ ពួកអង្គការជាមួយរដ្ឋាភិបាលហ្នឹងគេចាត់តាំងអ្នកស័គ្រ ដូចថា យើងអ្នកនៅតាមភូមិតាមអីមានជម្ងឺគ្រុនចាញ់អញ្ចឹងគេឲ្យថ្នាំឲ្យអីយកមកព្យាបាល តែបើជម្ងឺធ្ងន់គេឲ្យបញ្ជូនទៅ តែបើជម្ងឺស្រាលៗយើងជួសហើយយើងវៃថ្នាំនៅហ្នឹងហ្មង ។

សេងគាៈ ពូធ្វើជាមួយអង្គការបានប៉ុន្មានឆ្នាំហើយ?

ហេងៈ តាំងពីឆ្នាំ២០០៨ យូដែរហើយ ។

សេងគាៈ អញ្ចឹងកាលពូនៅភ្នំដងរែកហ្នឹង មានវៃញឹកញាប់ទេពូ?

ហេងៈ កាលចុះទៅបានវៃ ។

សេងគាៈ តែឡើងភ្នំពួន?

ហេងៈ អត់ពួនទេ ភូមិអញ្ចឹងដូចតែគ្នាហ្នឹង ប្រជាជនគេរស់នៅអញ្ចឹងដែរហ្នឹង តែផ្ទះវាតូចណាស់ ផ្ទះស្បូវតូចៗមួយគ្រួសារៗ ហើយកាលជំនាន់ហ្នឹងខ្ញុំអត់ទាន់មានប្រពន្ធផង ។

សេងគាៈ អញ្ចឹងពូយកប្រពន្ធនៅនេះឬក៏នៅនោះ?

ហេងៈ នៅនោះនៅខាងជីព្រះវិហារ ។

សេងគាៈ ទៅនៅហ្នឹងអ្នកណាគេជាអ្នកដឹកនាំ?

ហេងៈ អាហ្នឹងចូលមុំ តាម៉ុក ហើយ ។

សេងគាៈ តាម៉ុក នៅហ្នឹងដែរ?

ហេងៈ នៅហ្នឹងដែរ ។

សេង៉គា:	ដល់៩២បានមកនៅនេះ?

ហេង:	៩២គេដកមកនៅនេះ។

សេង៉គា:	ហើយ តាម៉ុក មកដែរ?

ហេង:	អត់មកទេ តាម៉ុក នៅនោះដដែលហ្នឹង។

សេង៉គា:	ហើយមកគ្នាប៉ុន្មាននាក់ទៅ មកនេះប៉ុន្មានកងពលទៅ?

ហេង:	ប៉ុន្មានភូមិហ្នឹង ភូមិថ្មី ឃុំថ្មី អូរដា ភូមិកណ្ដាល ស្វាយជ្រៃ អូរគគី។

សេង៉គា:	មាន៥ភូមិហ្នឹង?

ហេង:	បាទ!

សេង៉គា:	ប៉ុន្មានភូមិហ្នឹងមកទីនេះទាំងអស់?

ហេង:	បាទ! មកតាមគាត់។

សេង៉គា:	មកតាមពីណាគេ?

ហេង:	តាម តាសុន សេន។

សេង៉គា:	តាសុន សេន ហៅមកប៉ុណ្ណឹង?

ហេង:	បាទ!

សេង៉គា:	ហេតុអីបានជាមកតែ៥ភូមិហ្នឹង អ្នកផ្សេងទៀតអត់មកដោយសារតែអ្វី?

ហេង:	អត់ដឹងដែរ?

សេង៉គា:	អត់ដឹងមូលហេតុទេ?

ហេង:	បាទ!

សេង៉គា:	បើគេឲ្យមកក៏មកទៅ?

ហេង:	បាទ!

សេង៉គា:	គេប្រាប់ថាម៉េចពេលដែលមកហ្នឹង តាសុន សេន មានប្រាប់ថាម៉េចទេ?

ហេង:	គាត់ប្រាប់ថាមកនៅនេះ។

សេង៉គា:	គាត់ប្រាប់ថាឲ្យមកនៅនេះវិញ?

ហេង:	មកនៅនេះមកបញ្ជាគេហ្នឹងណា៎ ធ្វើមេគេហ្នឹងណា៎ គាត់មេធំដូច ហ៊ុន សែន អញ្ចឹងណា៎ គាត់មក១ក្ដាប់មួយភូមិភាគប៉ុន្មានកងពលហ្នឹងលើគាត់ គាត់ហ្នឹងក្រោមតា ប៉ុល ពត បើប៉ុល ពត បញ្ជាមកតាសុន សេន បញ្ជាតាមក្រោយ។

សេង៉គា:	តាសុន សេន គាត់ស្អងការ?

ហេង៖ បាទ! គាត់ក្ដាប់រួម ហើយតា ប៉ុល ពត គាត់នយោបាយ តាម៉ុក ផ្ទៃក្នុងទេគាត់មេបក្ស គេទេ ។

សេងគា៖ ចុះតា សុខ គង់?

ហេង៖ ហ្នឹងគាត់យូហើយ ខ្ញុំអត់ដឹងដែរគាត់មេកងពល នៅនេះ ។

សេងគា៖ ដល់ពេលតា សុន សេន មកនៅគាត់យ៉ាងម៉េចដែរបើគាត់នៅក្ដាប់អញ្ចឹង?

ហេង៖ ពិបាកដែរហ្នឹង ។

សេងគា៖ កាលហ្នឹងតា សុខ គង់ អត់សប្បាយចិត្តដែរ?

ហេង៖ បាទ! គេស្អប់ដែរហ្នឹង ពួកខ្ញុំនេះស្អប់ដែរហ្នឹង ។

សេងគា៖ កាលហ្នឹងស្អប់ដែរ?

ហេង៖ បាទ!

សេងគា៖ ហើយគាត់មានធ្វើអីទេកាលហ្នឹង?

ហេង៖ អត់មានធ្វើអីទេ គ្រាន់តែគេប្រើផែនការណ៍គេឲ្យទៅដញ្ជូនគ្រាប់ហ្នឹង ដល់ពេលបញ្ជូនទៅ គេយកទៅវៃហ្នឹង ដូចថាយើងនៅតាមភូមិអញ្ចឹងគេមិនឲ្យដញ្ជូនគ្រាប់ កម្លាំងមិនមែនអ្នក ប្រយុទ្ធណា ដល់ពេលអញ្ចឹងទៅអាមេ តាខៀវ ហ្នឹងវាមានឡានដឹកដញ្ជូនគ្រាប់ណា៎វា យកឯងទៅវៃចោល ។

សេងគា៖ តាខៀវ មួយណា?

ហេង៖ តាសុន សេន ហ្នឹង ។

សេងគា៖ អ៎ តាសុន សេន ហ្នឹងគេហៅ តាខៀវ?

ហេង៖ បាទ!

សេងគា៖ ហើយចុះ តាសុខ គង់ គេហៅអីគេ?

ហេង៖ សុខ គង់ ខ្ញុំអត់ដឹងដែរ សុខ គង់គេហៅបង១៨អញ្ចឹងទៅ ។

សេងគា៖ បង១៨?

ហេង៖ ហ្នឹងអើយ វមានម៉ូគេណា៎ ។

សេងគា៖ ដល់ពេលមកអញ្ចឹង សុខ គង់ គេវាងវិញអត់ឲ្យជ្រកនៅខ្សែត្រៀមទេ?

ហេង៖ អត់ទេ ចាំមើលណា៎ នេះមិន តាសុន សេន បញ្ជូនយើងទៅគេឲ្យដញ្ជូនគ្រាប់ឲ្យគេណា៎ ដល់មេនៅខាងមុខនោះមិនមែនឲ្យយើងដញ្ជូនគ្រាប់ណា៎

ពេលដឹកយើងទៅដល់ហ្នឹងគេយកយើងទៅដាក់នៅខ្សែត្រៀមណា៎ នៅទល់មុខខ្មាំងហ្នឹង ឡើងវៃឡើងអីនឹងគេទៅណា៎ ។

សេងគា: ចុះនៅអញ្ជឹងទៅ តាសុខ គង់ ស្លាប់តា សុន សេន ទេ?

ហេង: ឥលូវ តាសុន សេន ងាប់បាត់ហើយ ។

សេងគា: គាត់ស្លាប់បាត់ហើយ?

ហេង: បាទ!

សេងគា: គេបាញ់ស្លាប់មែន?

ហេង: គេបាញ់ តាប៉ុល ពត ហៅសម្លាប់ចោលអស់ហើយ ងាប់អស់ហើយមេៗមានសល់អី ។

សេងគា: អញ្ជឹងទៅនៅសល់តែតា សុខ គង់?

ហេង: ហ្នឹងអើយ ក្រោយមកងាប់បន្តៗ ។

សេងគា: តាសុខ គង់ ហើយហ្នឹង តាកន អ្នកណាធំជាង?

ហេង: អាហ្នឹងវាមួយផ្នែកម្នាក់ ប្រហែលជា តាកន ធំជាងមិនដឹង ។

សេងគា: តាកន ធំជាង សុខ គង់?

ហេង: បាទ!

សេងគា: ចុះ តាកន នៅរស់ទេ?

ហេង: នៅរស់តើ ។

សេងគា: ចុះឥលូវគាត់ធ្វើអីគេ ហើយនៅភូមិនេះទេ?

ហេង: តាកន នៅតាមភូមិដូង ។

សេងគា: ហើយគាត់ធ្វើអី តាសុខ គង់ ឡើងដល់ខេត្តហើយហ្នឹង ចុះ តាកន ធ្វើអី?

ហេង: តាកន មិនដឹងធ្វើអីអត់ដឹងដែរ ប៉ុន្តែកាលហ្នឹង តាកន ធំជាង តាកន ធំជាង តាគង់ ក្រោមគេហ្នឹង តាកន ចង់ប្រហែល តាម៉ុក ដែរហ្នឹង ។

សេងគា: នៅនោះពូយកប្រពន្ធគេរៀបឲ្យឬក៏ពូស្រលាញ់គ្នាហើយសុំគេរៀបការ?

ហេង: គេរៀបឲ្យ ។

សេងគា: ពីណាអ្នករៀបឲ្យ ប្រធានមែន?

ហេង: អាហ្នឹងខ្ញុំមកនៅខាង១០៥នេះវិញហើយ ។

សេងគា: ឈប់នៅខាងកងពលខាងរតនៈគិរីហើយ?

ហេង: ឈប់ហើយ ។

សេងគា៖ មកនៅខាង១០៥វិញ?

ហេង៖ បាទ!

សេងគា៖ ហើយពីណាគេអ្នកបញ្ជាខាងកងពល១០៥ហ្នឹង?

ហេង៖ តាវៀង ។

សេងគា៖ តាវៀង?

ហេង៖ ហ្នឹងអើយ គាត់ហ្នឹងជនជាតិ ។

សេងគា៖ អ៎គាត់ជនជាតិ?

ហេង៖ បាទ!

សេងគា៖ ចុះម៉េចបានជាគាត់មកកាន់កងពលបើគាត់ជាជាតិ ហើយគាត់ជាជនជាតិអីគេ?

ហេង៖ គាត់ជនជាតិលាវ គាត់ដូចតែជនជាតិខ្មែរដែរហ្នឹងព្រោះគាត់តស៊ូដែរហ្នឹង ។

សេងគា៖ ហើយគាត់មកកាន់ហ្នឹងទៅ?

ហេង៖ បាទ!

សេងគា៖ ហើយយកប្រពន្ធហើយមានកូននៅហ្នឹងទៅ ដល់ពេលគេសាមារណកម្មហើយបានមកនេះ ចុះមេញពូនិយាយពីរឿងដែលថានេះមេញ រឿងដូចថាចចារគ្នាមេញ?

ហេង៖ អាហ្នឹងនៅ១០៥ ក្រោយពីនៅ១០៥ហ្នឹងមកទៅនៅជំរុំមួយសារ ហើយបានមកនៅកន្លែងពេទ្យវិញ កន្លែងពេទ្យតា សុន សេន នេះហើយបានត្រលប់មកនេះ គេបញ្ជូនមកនេះ ។

សេងគា៖ ពូមកដល់នេះហើយបានទៅនៅជំរុំវិញ?

ហេង៖ អត់ទេ ចេញពីកងពលហ្នឹងមក មកនៅ១០៥ ចេញពី១០៥ទៅនៅជំរុំ ។

សេងគា៖ អ៎ពូទៅនៅជំរុំដែរ?

ហេង៖ ទៅនៅជំរុំ ចេញពីជំរុំមកនៅ១០៥នេះហើយបានមកនៅកន្លែងតា សុន សេន នេះវិញ

សេងគា៖ អញ្ចឹងពូនៅកន្លែងកងពល១០៥បានប៉ុន្មានឆ្នាំ ចេញពីហ្នឹងមក?

ហេង៖ បានយូដែរហ្នឹង បើគិតទៅតាំងពី៨៧មក ។

សេងគា៖ ៨៧រហូតដល់៩២មែន?

ហេង៖ ហ្នឹងអើយ ។

សេងគា៖ ចេញពីកងពលហ្នឹងមក?

ហេង៖ បាទ!

សេងគា: ហេតុអីបានជាពូចេញពីកងពល គេឲ្យចេញឬក៏ចង់ចេញ?

ហេង: គេអត់ឲ្យចេញទេ គឺខ្ញុំរត់ចេញមកតែម្តង រត់ជាមួយអ្នកស្គាល់ៗគ្នាហ្នឹង អ្នកនៅស្រុកភូមិជាមួយគ្នា ។

សេងគា: អ្នកណាខ្លះនៅភូមិជាមួយគ្នា?

ហេង: ស្គាល់គ្នាទៅតាម... ។

សេងគា: រត់មកជាមួយគ្នាទៅ?

ហេង: អត់ទេ គេនៅតំបន់ហ្នឹងណា៎ ។

សេងគា: ប៉ុន្តែពូរត់មក?

ហេង: បាទ! គេទើបតែចូលឆ្នាំ៧៥នេះ បែកភ្នំពេញហើយបានគេចូលហ្នឹង បើប្រពន្ធខ្ញុំតាំងពីមុនឆ្នាំ៧២មក ។

សេងគា: ដល់ពេលរត់មកអញ្ចឹងគេអត់មានតាមទេ?

ហេង: គេតាមដែរ ។

សេងគា: ហើយអត់អីទេ?

ហេង: ចុះមេគេលាក់ ចេះតែពួននេះពួននោះ ការហើយក៏អត់មានបានដេកជាមួយគ្នាដែរ ការហើយគេជម្លៀសទៅនោះ គេចទៅនេះគេចទៅនោះទៅដល់ហើយបានគេឈប់រក ។

សេងគា: ហើយមកជួបប្រពន្ធវិញទៅ?

ហេង: បាទ!

សេងគា: ហើយដល់ពេលចប់ពីហ្នឹងបាន៤-៥ឆ្នាំទៅបានទៅជំរុំវិញ?

ហេង: ហ្នឹងអើយ ទៅជំរុំមួយសារទៀត ។

សេងគា: ជំរុំខាងណា?

ហេង: ជំរុំអូរត្រាវ ។

សេងគា: យកមនុស្សទៅច្រើនទេកាលហ្នឹង?

ហេង: ច្រើនតើ មនុស្សរាប់ពាន់នាក់ដែរហ្នឹង ។

សេងគា: កាលហ្នឹងពូទៅតែឯងឬក៏យកប្រពន្ធទៅដែរ?

ហេង: ទៅទាំងប្រពន្ធទាំងកូន ។

សេងគា: កាលហ្នឹងមានតែកូនមួយទេ?

ហេង: កាលហ្នឹងបានកូនពីរហើយ ។

សេងគា:	ពូទៅជំរុំបានប៉ុន្មានខែ?

ហេង:	មិនដឹងបានប៉ុន្មានខែទេ ចាប់ពីឆ្នាំ៩០ទៅ បានប្រហែលជា១ឆ្នាំជាង។

សេងគា:	១ឆ្នាំជិត២ឆ្នាំ?

ហេង:	ហ្នឹងអើយ ដល់ឆ្នាំ៩២បានមកវិញ។

សេងគា:	ហើយនៅជំរុំហ្នឹងការហូបចុកអីយ៉ាងម៉េចដែរ?

ហេង:	គេបើកអង្ករឲ្យហូប។

សេងគា:	ខាងណាអ្នកបើក ចិនមែន?

ហេង:	អង្គការពួកបារាំង មួយអាទិត្យគេបើកម្តង អង្ករក្រហមៗ។

សេងគា:	អង្ករសម្រូប។

ហេង:	ហើយមានត្រីខ ទឹកដោះគោ មានមីអញ្ចឹងទៅ។

សេងគា:	ទៅនៅហើយបានរត់មកនេះវិញ?

ហេង:	គេរៀបរើជំរុំបានរត់មកនេះ។

សេងគា:	រត់មកជាមួយ សុន សេន អីហ្នឹង?

ហេង:	បាទ! ហើយបានគេបញ្ជូនមកនេះ។

សេងគា:	ដល់ពេលមកនៅហ្នឹងក៏ចប់រហូតទៅ?

ហេង:	បាទ! ចប់រហូត។

សេងគា:	តែភូមិនេះមុនដំបូងមិនមែនឈ្មោះភូមិនេះណា៎មែនទេ?

ហេង:	មិនមែនឈ្មោះភូមិនេះទេ គេដាក់ហ្នឹង គេដាក់អូរគគី កាលហ្នឹងសុទ្ធតែព្រៃទាំងអស់ហ្នឹង មានភូមិមកពីណា។

សេងគា:	ហើយម៉េចបានជាគេដាក់ភូមិអូរគគី?

ហេង:	ព្រោះមានអូរនៅជិតនេះ។

សេងគា:	ហើយសំបូរដើមគគី?

ហេង:	អត់ទេ តែគេដាក់ឈ្មោះអូរគគីហ្នឹងហ្នង។

សេងគា:	ឃើញអូរគេដាក់អូរគគីអញ្ចឹងទៅ?

ហេង:	អូរហ្នឹងឈ្មោះអូរគគី។

សេងគា:	ពីមុនមកគេហៅអូរគគីមែនកន្លែងហ្នឹង?

ហេង:	មានអូរគគី មានអូរចំបក់។

សេងគា:	ប្រហែលជាមានដើមគគីរនៅហ្នឹងបានគេដាក់អូគគី?

ហេង:	ប្រហែលជាមានដើមគគីច្រើនហើយ ។

សេងគា:	ដល់ពេលមានគគីអញ្ចឹងគេដាក់ភូមិហ្នឹងអូរគគីទៅ?

ហេង:	បាទ! ហើយអូរធំនេះគេហៅអូរដា ។

សេងគា:	ចុះដល់ពេលពូមកដល់នេះអញ្ចឹងគេឲ្យដីឲ្យអីចាប់ទៅ?

ហេង:	គេចែកដីឲ្យ គេចែកដីព្រៃហ្នឹងព្រោះនៅនេះសុទ្ធតែព្រៃហ្នឹង ។

សេងគា:	នៅនេះសុទ្ធតែព្រៃ?

ហេង:	បាទ! ព្រៃទាំងអស់អត់មានចូលចុះទេ ទទឹង៣០ម៉ែត្រ ហើយបណ្ដោយយើងមួយហាត់ៗ មួយបួង់ៗគេកាប់យកទៅ ។

សេងគា:	កាលហ្នឹងគេចែកដីប៉ុន្មាន?

ហេង:	មួយគ្រួសារមួយហិចតា ។

សេងគា:	ទទឹងមែន?

ហេង:	ទទឹង៣០ ហើយបណ្ដោយធ្វើម៉េចឲ្យបានមួយហិចតា ។

សេងគា:	ដឹងតែទទឹង៣០ ហើយបណ្ដោយក្រោយទៅ?

ហេង:	បាទ!

សេងគា:	កាប់បានប៉ុណ្ណាយកប៉ុណ្ណឹងទៅ?

ហេង:	បាទ!

សេងគា:	ដល់ពេលមកដល់នេះធ្វើអី ធ្វើចំការរហូតមែន?

ហេង:	ធ្វើចំការរហូត ។

សេងគា:	អត់មានធ្វើពេទ្យធ្វើអីទេពេលមកដល់នេះ?

ហេង:	អត់មានធ្វើផង ។

សេងគា:	ធ្វើចំការធ្វើអីទៅ?

ហេង:	ធ្វើពេទ្យបានប៉ុន្មានខែដែរហ្នឹង កាលហ្នឹងខ្ញុំទៅស្រុកថាទៅនៅជាមួយម្ដាយហ្នឹងក៏ត្រលប់មកវិញគេថាឈប់ឲ្យធ្វើឈប់អីទៅព្រោះមានមនុស្សមានអីគេដាក់អញ្ចឹងណា៎ ហើយខ្ញុំឈប់ធ្វើទៅ គេហៅឲ្យចូលដែរតែខ្ញុំឈប់ធ្វើ ។

សេងគា:	ចុះពូព្រុថាចចារជាមួយកំពីងពួយម៉េចនោះ?

ហេង:	អាហ្នឹងឆ្នាំ៩៦ ។

សេដ៏គា៖ កាលហ្នឹង៩២នៅបាញ់គ្នានៅឡើយទេ?

ហេង៖ នៅបាញ់គ្នា ។

សេដ៏គា៖ ដល់ពេលឆ្នាំ៩៦ ហើយពីណាគេអ្នកទៅចចារ?

ហេង៖ មេៗគេទៅ ។

សេដ៏គា៖ ពូមានទៅទេ?

ហេង៖ ខ្ញុំទៅដែរហ្នឹង កាលហ្នឹងជូនគេទៅ ។

សេដ៏គា៖ កាលហ្នឹងមានគ្នាប៉ុន្មាននាក់ទៅចចារហ្នឹង?

ហេង៖ មានគ្នា១២នាក់ ។

សេដ៏គា៖ ពូមាននៅចាំឈ្មោះទេ?

ហេង៖ ភ្លេចអស់ហើយ ។

សេដ៏គា៖ ប៉ុន្តែមេពីណាគេ?

ហេង៖ មេពួក តាម៉ន ហ្នឹង ។

សេដ៏គា៖ មាន តាម៉ន ហើយមានពីណាទៀត?

ហេង៖ មាន តាប៉ន ហើយមានប៉ុន្មាននាក់ទៀតទេ តែឥលូវងាប់អស់ហើយនៅតែ តាម៉ន មួយទេ ។

សេដ៏គា៖ តាម៉ន គាត់នៅឯណារាល់ថ្ងៃ?

ហេង៖ នៅហួសផ្សារខ្សែមបន្តិចហ្នឹង ។

សេដ៏គា៖ គាត់ធ្វើអីរាល់ថ្ងៃ តាម៉ន ហ្នឹង ហើយគាត់ឈ្មោះអី ម៉ន?

ហេង៖ មិនដឹងឈ្មោះអី ម៉ន ព្រោះគាត់ចៅហ្វាយស្រុក ។

សេដ៏គា៖ អ៎ គាត់ចៅហ្វាយស្រុកដែរ?

ហេង៖ អ៎គាត់ជាក្រុមប្រឹក្សា ។

សេដ៏គា៖ ខែ៦ចចារ?

ហេង៖ បាទ!

សេដ៏គា៖ ចចារជាមួយពីណាគេកាលហ្នឹង?

ហេង៖ ជាមួយទាហានៗ ដល់ហើយគេដកមេៗទៅមិនដឹងទៅចចារជាមួយពីណា ហើយពេលទៅដល់កំពីងពួយហ្នឹងគេឡដេកហ្នឹងហើយគេយកតែមេៗទៅ ។

សេដ៏គា៖ យក តាប៉ន អីហ្នឹង?

ហេង៖ មាន តាម៉ន, តាប៉ន ។

សេងគា៖ ហើយមានពីណាទៀតទេ?

ហេង៖ អត់ស្គាល់ទេ ។

សេងគា៖ ហើយ តាម៉ន នៅរស់?

ហេង៖ នៅរស់ ។

សេងគា៖ ហើយពូទៅដល់ណាបានគេឲ្យឈប់ ព្រោះពូអត់បានទៅដល់កន្លែងចចារទេ គេឲ្យតែមេៗទៅទេ?

ហេង៖ គេឲ្យមេៗទៅ ។

សេងគា៖ តែពូទៅដល់កន្លែងណាទៅ?

ហេង៖ ភ្នំកំពីងពួយ ។

សេងគា៖ ទៅដល់ភ្នំកំពីងពួយ?

ហេង៖ ទៅដល់គេឲ្យដេកនៅលើហ្នឹង ។

សេងគា៖ ទាំងមេៗធំហ្នឹង?

ហេង៖ ហ្នឹងអើយទាំងមេទាំងអីហ្នឹង ។

សេងគា៖ ចុះម៉េចបានជាគេឲ្យពូទៅដែរ កាលហ្នឹងពូធ្វើអីគេ?

ហេង៖ អត់មានធ្វើអីផង ។

សេងគា៖ ប៉ុន្តែម៉េចគេឲ្យទៅ?

ហេង៖ ចុះកម្លាំងកន្លែងខ្លះគេឲ្យទៅ ហើយខ្លះទៀតគេអត់ទៅ ។

សេងគា៖ អញ្ចឹង?

ហេង៖ បាទ! គេចាត់តាំងទៅ ។

សេងគា៖ គេចាត់តាំងឲ្យទៅ?

ហេង៖ ប៉ុន្តែជំនាន់ហ្នឹងនៅធ្វើពេទ្យ ។

សេងគា៖ ពូនៅធ្វើពេទ្យតែគេចាត់តាំងឲ្យទៅ?

ហេង៖ បាទ!

សេងគា៖ ដល់ពេលចចារទៅបានសម្រេច?

ហេង៖ ដល់ពេលចចារទៅគ្មានវៃគ្នានា ឈប់វៃគ្នាហើយ ដល់ពេល សុខ គង់ ហ្នឹងចូលគណៈបក្សប្រជាជនទៅ មុនដំបូងពួកប៉ៃលិនគេមកគំរាមដែរហ្នឹង ។

សេងគា៖ ពួកប៉ៃលិនខាងអ៊ុំឈាន?

ហេង៖ បាទ!

សេងគា៖ អត់ឲ្យចូល?

ហេង៖ អត់ឲ្យចូលអី គេតាមដានយើងកុំឲ្យរកស៊ីអីហ្នឹងណា៎ ទៅយាមនៅកន្លែងច្រកផ្លូវបំបែកហ្នឹង ពួកហ្នឹងបើករថក្រោះមកមិនបាច់យាមអីទេ ពួកយើងប្រជាជនទៅដេកទៅ ហើយក៏នាំគ្នាមកដេកអស់មក មិនដឹងគេរកចាប់អ្នកណាកាលហ្នឹង ប្រហែលជា តាម៉ុក ហើយ ។

សេងគា៖ ដល់ពេលហ្នឹងមកក៏ សុខ គង់ ចូលទៅជាមួយគណៈបក្សប្រជាជនទៅក៏ឈប់បាញ់ទៅ?

ហេង៖ បាទ!

សេងគា៖ ហើយអ៊ុំឈានចូលដែរ?

ហេង៖ អ៊ុំឈានចូលដែរទៅ ។

សេងគា៖ ហើយក៏ស្ងប់ស្ងាត់អស់ទៅ ។

ហេង៖ ស្ងប់ស្ងាត់ទាំងអស់គ្នាស្រួលណាស់ ។

សេងគា៖ ហើយតាំងពីហ្នឹងមករហូតដល់បច្ចុប្បន្នពូធ្វើស្រែចំការរហូតទៅ?

ហេង៖ ធ្វើស្រែចំការរហូត ។

សេងគា៖ ហើយពូពុថាបងប្អូនពូស្លាប់អស់ គេយកទៅសម្លាប់នោះ?

ហេង៖ អាហ្នឹងជំនាន់ខ្មែរក្រហម ។

សេងគា៖ នៅឆ្នាំប៉ុន្មានទៅ?

ហេង៖ ឆ្នាំប៉ុន្មានទេ ប្រហែលឆ្នាំ៩០មិនដឹង ។

សេងគា៖ អ៊ំ៩០ជាងហើយហ្នឹង?

ហេង៖ បាទ! ជិតយួនចូលហើយហ្នឹង ។

សេងគា៖ ហើយគាត់ស្លាប់នៅណាវិញ ស្លាប់នៅព្រៃកប្បាសមែន?

ហេង៖ ស្លាប់នៅព្រៃកប្បាសហ្នឹង ស្លាប់នៅភូមិហ្នឹង ។

សេងគា៖ ពូមានដឹងថាមូលហេតុអីបានជាគេយកទៅសម្លាប់ចោលទេ?

ហេង៖ បើតាមពុប្រជាជននិយាយគេថាចៃខ្ញុំហ្នឹងនៅខាងនោះស៊ីងណា៎ ដល់ពេលកន្លែងដែលយួនជិតចូលហ្នឹង វាកាលហ្នឹងជំនាន់ហ្នឹងគេមិនចាប់ចាស់ៗសហ្នឹងព្រោះគេថាខ្សែចិនខ្សែយួនអីហ្នឹងមិនខ្មែរក្រហមចាប់វៃចោល ដល់ពេលអញ្ចឹងបងប្អូនវាសៗដែរក៏គេចោទថាខ្សែចិនខ្សែយួនទៅ ហើយពួកខ្មែរក្រហមហ្នឹងគ្រាន់តែហៅមកគិបទាំងកូនទាំងចៅហ្នឹងចងខ្សែ

អន្រើន ហើយព្រលឹមឡើងវ៉ៃចោលតែម្ដងនាប់អស់ ដាក់រណ្ដៅ ហើយម៉ែខ្ញុំចាស់ៗហ្នឹង គេជម្លៀសថាឲ្យហូបបបរស្ករសិនហ្នឹង ដែលខ្ញុំថាខ្ញុំសួរពួកគាត់ទេណា៎ ៗៗ

សេងគា: អ៊ំ! ពូសួរម្ដាយរបស់ពូ?

ហេង: បាទ!

សេងគា: ពូសួរនៅឆ្នាំណា?

ហេង: នៅឆ្នាំ៩២-៩៣នេះហើយបានខ្ញុំទៅលេងផ្ទះ អាស៊ំ៩៦បានខ្ញុំទៅលេងផ្ទះ ដល់ឆ្នាំ៩៦ បានដឹងថាចាស់ៗគេឲ្យហូបបបរស្ករ ហើយដល់អញ្ចឹងបានប្រហែលជា២-៣ថ្ងៃហ្នឹងបាន យួនចូលមកពេញហើយរំដោះអស់ទៅ ហើយក៏រួចទៅនៅម្ដាយហ្នឹងទៅ ។

សេងគា: ដល់៩០ជាងហើយបានរំដោះ?

ហេង: ៩០ជាងអាជិតយួនចូលហ្នឹង នៅខ្មែរក្រហមដែរហ្នឹង វាដាក់ផ្ដាច់ព្រលឹងចុងក្រោយហ្នឹង ហើយយើងនេះទាល់តែ៩៦-៩៧ហើយបានទៅលេងផ្ទះហ្នឹង វាផុតអស់ហើយហ្នឹង ។

សេងគា: ហើយកូនចៅពូអត់មានជួបបញ្ហាឈឺស្កាត់អីទេ?

ហេង: វាឈឺដែរតែអត់អីទេ ឈឺមានអីមានតែគ្រុនក្ដៅហ្នឹង អាមួយនោះ ។

សេងគា: គ្រុនក្ដៅ ឬក៏គ្រុនយើងធម្មតា?

ហេង: គេថាគ្រុនស្វិត ព្រោះកាលហ្នឹងយើងអត់មានប៉ូរីយ៉ូចាក់ ។

សេងគា: ពូដឹងដែរតែអត់មានអីចាក់?

ហេង: ដឹងដែរតែវាអត់មានអីចាក់ ថ្នាំប៉ូរីយ៉ូហ្នឹងមានតែថ្នាំបារាំង ហើយបារាំងគេមាននេះណា ជិនាន់ហ្នឹង ។

សេងគា: អញ្ចឹងអត់ដឹងដែរ?

ហេង: អត់ដឹង កាលហ្នឹងទៅដេកពេទ្យយូដែរហ្នឹង ដល់ពេលកូនធំដែរហើយឲ្យកូនលើកដៃមក លើកអត់រួច ដល់ហើយបានថាកូនស្វិតដៃម្ខាង ហើយអត់ទាន់ដឹងថាស្វិតទៀតទាល់តែ បាន២-៣ឆ្នាំបានវាស្វិត វាដូចធ្លាក់ក្រឡេម៉េច ប៉ុន្ដែឥលូវធំហើយវាអាយុ១៦ហើយ ។

សេងគា: ហើយដៃហ្នឹងអត់មានអន្ដការណាមើលទេ?

ហេង: មើលដែរតែមើលអត់យល់ ។

សេងគា: អញ្ចឹង?

ហេង: ហ្នឹងអើយ ។

សេងគា: ហើយមួយទៀតក៏ចង់សួរពូ ឥលូវហ្នឹងគេមិនកាត់ទោស គេកាត់ទោសមេដឹកនាំធំៗណា៎ ខ្មែរក្រហមនៅតុលាការអញ្ចឹង បើតាមគំនិតពូតើពូយល់ឃើញយ៉ាងម៉េចដែរ?

ហេង: ខ្ញុំមិនសូវយល់ដែរហ្នឹង ។

សេងគា: ពូគិតថាកាត់ទោស?

ហេង: កាត់ទោសទៅទាល់តែ ហ៊ុន សែន ជាប់ដែរព្រោះហ៊ុន សែន ខ្មែរក្រហមដែរកាលពីមុន អាហ្នឹងយើងនិយាយឲ្យចំទៅណា៎ ព្រោះខ្មែរក្រហមទាំងអស់គ្នាគ្រាន់តែថាខាងរដ្ឋកម្ពុជា អញ្ចឹងសម្រុះសម្រួលខ្មែរយើងឲ្យត្រូវគ្នាអញ្ចឹងណា៎ ហើយឈប់វ៉ៃគ្នាអញ្ចឹងទៅ ប៉ុន្តែពីមុនខ្មែរក្រហមដូចតែគ្នា អញ្ចឹងខ្មែរយើងមានតែសម្រុះសម្រួល ។

សេងគា: អញ្ចឹងពូគិតថាការកាត់ទោសអញ្ចឹងមិនសូវល្អទេមែនទេ?

ហេង: កាត់ទោសអញ្ចឹងមិនសូវល្អដែរហ្នឹង ប៉ុន្តែបើមិនធ្វើអញ្ចឹងគេមិនជួយលុយទេ ហើយបើយើងកាត់ទោសអញ្ចឹងគេមកចង់ដឹងអញ្ចឹងគេជួយលុយជួយអីអញ្ចឹង ។

សេងគា: តែបើតាមគំនិតពូផ្ទាល់ពូគិតថាអត់សូវសមស្របទេ?

ហេង: អត់សមស្របទេកាត់ទោសខ្មែរក្រហម ។

សេងគា: ពូគិតថាខ្មែរក្រហមជាជនរងគ្រោះដែរ?

ហេង: ជនរងគ្រោះដែរហ្នឹង ។

សេងគា: អញ្ចឹងគេកាត់តែធំៗទេ បើកាត់តូចៗមានតែកាត់ពេញមួយប្រទេស?

ហេង: បើកាត់តូចៗចប់អស់ហើយ ។

សេងគា: អ្នកណាក៏ខ្មែរក្រហមដែរបើកាត់ទាំងអស់ តែគេកាត់តែធំៗទេដើម្បីបង្ហាញនិងបញ្ឈប់ទប់ស្កាត់អំពើរហ្នឹងដើម្បីកុំឲ្យកើតម្តងទៀតណា៎ ដូចពូផ្ទាល់ពូចង់ឲ្យកើតទៀតទេ?

ហេង: អត់ចង់ឲ្យកើតទេ អញ្ចឹងបានថាដូចខ្ញុំនិយាយម៉េញហ្នឹង បើកាត់ទោសខ្មែរក្រហមទាល់តែកាត់ទាំងអស់គ្នា សូម្បីតែអ្នកក្នុងហ្នឹងក៏មានខ្មែរក្រហមដូចគ្នាដែរ ពីមុនខ្មែរក្រហមដូចតែគ្នាហ្នឹង គ្រាន់ថាយើងចង់សម្រុះសម្រួលគ្នាដូចថាខ្មែរហ្នឹងកុំឲ្យវាទាស់គ្នាទៀត យើងសម្រុះសម្រួលគ្នាទៅ ឈប់វ៉ៃឈប់អីគ្នាអញ្ចឹងទៅណា៎ បើសិនជាយើងនៅមានខ្មែរក្រហមខ្មែរសហ្នឹងមិនស្រួលហ្នឹងនៅតែគ្រហឹមដាក់គ្នាទៀត អញ្ចឹងបានថាកុំឲ្យមានក្រហមមានសអីមានតែខ្មែរតែមួយរួបរួមជាតិគ្នាតែមួយអញ្ចឹងទៅយើងវាស្រួលណា៎ ។

សេងគា: អញ្ចឹងពូគិតថាការកាត់ទោសហ្នឹងមិនសូវទំនងប៉ុន្មានទេ?

ហេង: មិនទំនងទេ ហើយអត់សមទៀត ។

សេងគា: បើមិនកាត់ហើយកាត់ តើមួយណាល្អជាង តាមគំនិតរបស់ពូ?

ហេង: វាពិបាកនិយាយដែរហ្នឹង បើថាកាត់ទៅវាអត់សបស្រម តែបើមិនកាត់ខាងមេៗគេ បើយើងខាងក្រោមនេះវាអត់មានអីត្រូវគិត ព្រោះរឿងកាត់ទោសខ្មែរក្រហមហ្នឹងវារឿងៗ

សេងគា: ពេលដែលគេកាត់ទោសមេធំៗអញ្ចឹងពូមានអារណិតគេទេ?

ហេង: អាណិតអីបើគាត់ត្រូវតែអញ្ចឹងហើយ ។

សេងគា: អញ្ចឹងពូទុកឲ្យតាមច្បាប់វិញ?

ហេង: បាទ!

សេងគា: ខ្ញុំដូចជាអស់សំនួរអីសួរពូហើយ តើពូមានសំនួរឬក៏មានអីចង់ប្រាប់ខ្ញុំទេ មានទេពូ?

ហេង: មិនមានអីសួរទេ គ្រាន់តែឆ្ងល់ថាសួរហ្នឹងសួរដើម្បីអី?

សេងគា: ដូចខ្ញុំប្រាប់ពូម៉េញអញ្ចឹង សួរហ្នឹងគឺសួរដើម្បីចងក្រងជាឯកសារ អត់មានពាក់ព័ន្ធនឹងរឿងនយោបាយទេ ខាងខ្ញុំខាងឯកសារស្រាវជ្រាវផ្ទុកឯកសារអញ្ចឹងណា៎ ដូច្នេះហើយសួរតែរឿងឯកសារហើយនឹងសាច់រឿងរបស់ពូដូចជារឿងនេះអញ្ចឹង ហើយឈ្មោះឪពុករបស់ខ្ញុំក៏ខ្ញុំអាចសរសេរចុះដែរ អញ្ចឹងពូមានបាត់ចំងល់នូវពូ មានអីទេពូ បើឆ្ងល់អាចសួរបានមិនបាច់លាក់លៀមនាំតែភ័យខ្លាចទេពូ?

ហេង: អត់មានអីទេ ឆ្ងល់តែប៉ុណ្ណឹងឯង ឆ្ងល់ត្រង់ថាកាត់ទោសកាត់អីហ្នឹង អាហ្នឹងរឿងមេៗទេ តែបើយើងខាងក្រោមមិនត្រូវកាត់ទេ ។

សេងគា: អាហ្នឹងគ្រាន់តែសួរពូដើម្បីចង់ដឹងពីយោបល់របស់ពូទេ ។

ហេង: ឆ្ងល់ដែរហ្នឹងដល់ពេលសួរអញ្ចឹង ឆ្ងល់ក្រែងលមានបញ្ហាអីចុងក្រោយថាអានេះប្រវត្តិខ្មែរក្រហមអញ្ចឹងណា៎ ។

សេងគា: អត់ទេ បើខ្មែរក្រហមមួយណាក៏ខ្មែរក្រហមដែរ នៅភូមិក៏សួរដែរ ភាគច្រើនគឺអញ្ចឹង ។

ហេង: ចាស់ហើយមិនភ័យអីទេ ។

សេងគា: ការកាត់ទោសហ្នឹងគឺគោលបំណងដើម្បីបង្ហាញបរទេសថាអំពើរពីមុនមក ហើយគេកាត់ទោសអ្នកដឹកនាំហ្នឹងគឺជាអ្នកដែលធ្វើខុស ដឹកនាំប្រទេសឲ្យបែបហ្នឹង ហើយមួយទៀតដើម្បីទប់ស្កាត់ក្មេងៗជំនាន់ក្រោយឲ្យបានដឹងបានយល់របបហ្នឹង ដូចពូអញ្ចឹងកូនពូជួនកាលអត់ជឿទេ?

ហេង: អត់ជឿទេ ។

សេងគា: ហូបបបរហូបអីមានអ្នកណាជឿ ។

ហេង៖ វាអត់ជឿទេ ។

សេងគា៖ អញ្ចឹងហើយបានគេមានសៀវភៅចងក្រងពីរឿងខ្មែរក្រហម ។

ហេង៖ ពួកខ្ញុំកាលហ្នឹងស៊ីគល់ចេក គល់ល្ហុង ។

សេងគា៖ អញ្ចឹងហើយបានខាងខ្ញុំចុះមកស្រាវជ្រាវ តែអត់អស់ទេព្រោះបានមួយភូមិ២-៣នាក់ហ្នឹង ហើយមិនមែនតែមួយខេត្តទេចង់គ្រប់ខេត្ត អញ្ចឹងទៅដើម្បីចងក្រងទុកជាឯកសារទុកឲ្យក្មេងៗជំនាន់ក្រោយបានដឹងបានយល់បានរៀន ហើយខ្ញុំហ្នឹងកាលពីលើកមុនក៏ខ្ញុំអត់ជឿដែរ ទាល់តែបានធ្វើការជាមួយ ហើយឯកសារអីបានឃើញអញ្ចឹងទៅបានដឹងថាអញ្ចឹងមែន អ្នកខ្លះអត់មានហូបទាល់តែមែនទែនណាពូ កើតទៅជាជម្ងឺហើមជម្ងឺអី ។

ហេង៖ អាហ្នឹងរឿងខ្លះខាតបើតាមពិនិត្យមើលវាមិនមែនចេះតែខាតទេ អាខ្លះវាដូចគំនិតអត់កើតដែរហ្នឹងក្នុងភូមិយើងហ្នឹង មិនមែនចេះតែថាគេទេ បើគំនិតកើតហើយយើងខំធ្វើការគិតគូសន្សំសំចៃឲ្យវាដឹងតាមស្រួល ដូចថាឲ្យដឹងថាចាយអីត្រូវចំនេញហើយចាយអីត្រូវខាត ដូចថាខ្លះចាយមិនគិត យកលុយគេមកធ្វើចំការមិនធ្វើចំការលេងយកលុយគេទៅចាយ ទាល់តែអញ្ចឹងជំពាក់គេហើយធ្វើផលមិនបានរឿងចំការដាក់មួយឆ្នាំអញ្ចឹងទៅ បើសិនជារាំង ឧទាហរណ៍ដូចខ្ញុំអញ្ចឹងដាំពោតរាំងមួយសារអញ្ចឹងទៅ ហើយយកលុយគេមកតែដាក់លើកទី២ដឹងតែចប់ហើយ អញ្ចឹងហើយអ្នកក្រ មិនមែនក្រមកពីនេះទេ ។

សេងគា៖ ខ្លះការប្រាក់ការអីធនាគារ ។

ហេង៖ រឿងការប្រាក់ហ្នឹងអើយ យើងយកមកយកឲ្យចំទិស គ្រាន់ថាចាយវាយហ្នឹងឲ្យវាសមបើយើងយកមកទិញអង្ករ ទិញខោអាវស្លៀកពាក់ ហើយទិញរបស់ប្រើប្រាស់ចំការទៅដល់បន្តិចបន្តួចហើយធ្វើចំការអត់កើតទៀតច្បាស់ជាវិនកហើយ ។

សេងគា៖ អញ្ចឹងអរគុណពូច្រើនដែលបានចំណាយពេលវេលាសំណេះសំណាលជាមួយខ្ញុំ ។

ហេង៖ បាទ!